ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិអេកូទេសចរណ៍

## ២០១៩-២០៣០

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨

## មាតិកា


**១- សេចក្តីផ្តើម** ........................................................................ **៣**

**២- ចក្ខុវិស័យ** ........................................................................ **៦**

**៣- គោលបំណងនិងគោលដៅ** ........................................................................ **៦**

៣.១- គោលបំណង ........................................................................ ៦

៣.២- គោលដៅ ........................................................................ ៦

**៤- យុទ្ធសាស្ត្រអភិវឌ្ឍអេកូទេសចរណ៍កម្ពុជា** ........................................................................ **៩**

៤.១- ធ្វើផែនការនិងបែងចែកជាតំបន់អេកូទេសចរណ៍អាទិភាព និងរៀបចំរមណីយដ្ឋានអេកូទេសចរណ៍គំរូ ........................................................................ ១០

៤.២- ការបង្កើនលទ្ធភាពធ្វើអាជីវកម្មនិងវិនិយោគទេសចរណ៍ក្នុងរមណីយដ្ឋានអេកូទេសចរណ៍.. ១១

៤.៣- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (រូបវន្តនិងទន់) និងការវិភាគសមត្ថភាពផ្ទុកក្នុងរមណីយដ្ឋានអេកូទេសចរណ៍ ........................................................................ ១២

៤.៣.១- យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទន់ ........................................................................ ១២

៤.៣.២- យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ........................................................................ ១២

៤.៤- ការអភិវឌ្ឍនិងការពង្រឹងគុណភាពសេវាកម្មទេសចរណ៍ក្នុងរមណីយដ្ឋានអេកូទេសចរណ៍. ១២

៤.៥- ការសិក្សាទីផ្សារនិងការផ្សព្វផ្សាយអេកូទេសចរណ៍ ........................................................................ ១៣

៤.៦- ការធានាសុវត្ថិភាពនៅតាមរមណីយដ្ឋានអេកូទេសចរណ៍ ........................................................................ ១៤

៤.៧- ការបញ្ជ្រាបការយល់ដឹងនិងការអប់រំអំពីអេកូទេសចរណ៍ ........................................................................ ១៤

**៥- ផែនការសកម្មភាព** ........................................................................ **១៥**

៥.១- ការបង្កើតនិងការពង្រឹងយន្តការស្ថាប័ន ........................................................................ ១៥

៥.២- ការកសាងសមត្ថភាព ........................................................................ ១៨

៥.៣- យន្តការគាំទ្រហិរញ្ញវត្ថុ ........................................................................ ១៨

៥.៤- ការរៀបចំក្របខណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ........................................................................ ១៨

៥.៥- ដំណើរការអនុវត្តគោលនយោបាយ ........................................................................ ១៩

**៦- ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ** ........................................................................ **១៩**

**៧- សេចក្តីសន្និដ្ឋាន** ........................................................................ **២០**

**សន្ទានុក្រម** ........................................................................ **២១**

**៨- ឧបសម្ព័ន្ធ : តារាងវិធានការគោលនយោបាយ** ........................................................................ **២៣**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# អារម្ភកថា

ក្នុងរយៈពេលប្រមាណពីរទសវត្សរ៍កន្លងមកនេះ កម្ពុជាមានសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់ពេញលេញ និងមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ក្នុងនោះវិស័យទេសចរណ៍មានការរីកចម្រើនគួរជាទីមោទនៈ។ វិស័យទេសចរណ៍កម្ពុជាដែលជា “**ទេសចរណ៍វប្បធម៌ និងធម្មជាតិ**” ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកជាវិស័យអាទិភាពមួយ ដើរតួជា “**មាសបៃតង**” រួមចំណែកដល់**ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម** និង**ការការពារបរិស្ថាន** ពោលគឺចូលរួមដល់ការកសាងសេដ្ឋកិច្ចបៃតងនៅកម្ពុជា ដែលជាផ្នែកគាំទ្រដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ (UN)។

វិស័យអេកូទេសចរណ៍នៅកម្ពុជាដែលជាផ្នែកមួយនៃទេសចរណ៍ គឺជាទីផ្សារថ្មីមួយដែលងើបឡើង (Niche Market) ស្របនឹងនិន្នាការអេកូទេសចរណ៍ នៅលើពិភពលោកទាំងមូលដែរ បើតាមការព្យាកររបស់អង្គការទេសចរណ៍ពិភពលោក (UNWTO) មានការកើនឡើងជាលំដាប់ប្រមាណជា២០% រៀងរាល់ឆ្នាំ ខណៈដែលទេសចរណ៍វប្បធម៌មានកំណើនតែ ៦%ប៉ុណ្ណោះ។ ការអភិវឌ្ឍអេកូទេសចរណ៍និងសហគមន៍ទេសចរណ៍ គឺជាយន្តការមួយដ៏សមស្របសម្រាប់ការអភិវឌ្ឍនិងអភិរក្សតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព និងផ្តល់ឱកាសឱ្យប្រជាពលរដ្ឋមូលដ្ឋានអាចចូលរួមយ៉ាងសកម្មក្នុងការសម្រេចចិត្តឬអាចនិយាយបានថាជាការផ្តល់នូវសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ (Local Empowerment) ដោយប្រជាពលរដ្ឋអាចទទួលផលប្រយោជន៍ដោយផ្ទាល់ពីទេសចរណ៍ប្រកបដោយសមធម៌ចូលរួមក្នុងការសម្រេចចិត្តអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន បង្កើននូវកម្រិតជីវភាព និងចូលរួមដល់ការកាត់បន្ថយចំណាកស្រុកប្រកបដោយប្រសិទ្ធភាព។

ទន្ទឹមនឹងនេះ ដើម្បីចាប់យកកាលានុវត្តភាពពីសក្តានុពលនៃធនធានធម្មជាតិរបស់កម្ពុជា ក៏ដូចជាដើម្បីប្រែក្លាយឱ្យតំបន់ការពារធម្មជាតិក្លាយជាផលិតផលទេសចរណ៍ ប្រកបដោយភាពច្នៃប្រឌិតនិងនវានុវត្តភាព រាជរដ្ឋាភិបាលកម្ពុជារៀបចំ**គោលនយោបាយជាតិអេកូទេសចរណ៍ ២០១៩-២០៣០** សំដៅដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រគន្លឹះនានាដើម្បីកែច្នៃតំបន់ការពារធម្មជាតិឱ្យក្លាយជាគោលដៅទេសចរណ៍ដ៏ទាក់ទាញ និងបានជាប្រយោជន៍ដល់ប្រជាពលរដ្ឋមូលដ្ឋានប្រកបដោយសមធម៌ និងដោះស្រាយនូវបញ្ហាគន្លឹះមួយចំនួនដែលកើតមានរវាងផ្នែកសាធារណៈ ក្រុមហ៊ុនឯកជន និងប្រជាពលរដ្ឋមូលដ្ឋានពោលគឺដាក់ចេញនូវគំរូ (Model) សម្រាប់កិច្ចសហការ (4Ps: Public- Private- People- Partnership) ពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ រាប់ទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់(ផ្លូវចូល សម្បទាទ្រទ្រង់) ការរៀបចំសេវាទេសចរណ៍ ការបណ្តុះបណ្តាលជំនាញ ការបង្កើតមុខរបរពាក់ព័ន្ធដល់ប្រជាពលរដ្ឋមូលដ្ឋាន ការស្វែងរកទីផ្សារសម្រាប់សហគមន៍ និងជាពិសេស គំរូស្វែងរកទុន (ធនធានហិរញ្ញវត្ថុ) សម្រាប់ឱ្យសហគមន៍មូលដ្ឋានអាចវិនិយោគនិងអភិវឌ្ឍសេវាកម្មបម្រើឱ្យភ្ញៀវទេសចរបាន។

ឯកសារគោលនយោបាយមួយនេះ មានតួនាទីជាប្រទីបបំភ្លឺផ្លូវដោយដាក់ចេញនូវធាតុសំខាន់ៗដើម្បីធានានូវគុណភាពនៃផលិតផល និងសេវាកម្មទេសចរណ៍ ការការពារ និងអភិរក្សបរិស្ថាន ក៏ដូចជាប្រពៃណី វប្បធម៌របស់ប្រជាជននៅតាមមូលដ្ឋាន និង**ការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌ និងតម្លាភាព** ព្រមទាំងយន្តការដើម្បីធានាឱ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់ប្រជាជននៅក្នុងមូលដ្ឋាន ឈរលើអភិក្រម 4Ps ស្របតាមស្មារតីនៃគោលនយោបាយ**ឈ្នះ-ឈ្នះទាំងអស់គ្នា** ក្នុងការអភិវឌ្ឍវិស័យអេកូទេសចរណ៍។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវគំរូអភិវឌ្ឍអេកូទេសចរណ៍នៅកម្ពុជាផ្អែកលើគំរូ២ជាមូលដ្ឋានៈ

- **គំរូអភិវឌ្ឍអេកូទេសចរណ៍ខ្នាតតូច(ដោយផ្អែកលើសហគមន៍មូលដ្ឋាន)** : ជាយន្តការមួយដ៏សមស្របសម្រាប់ការអភិវឌ្ឍក្នុងតំបន់ធម្មជាតិមួយ ដែលមានប្រជាពលរដ្ឋមូលដ្ឋានរស់នៅផ្សារភ្ជាប់ទៅនឹងធម្មជាតិក្នុងកម្រិតអតិបរមា ដែលការអភិវឌ្ឍនេះនឹងធ្វើឱ្យគ្រប់ភាគីពាក់ព័ន្ធ ពិសេស ប្រជាពលរដ្ឋមូលដ្ឋានអាចចូលរួមយ៉ាងសកម្មតាមរយៈការផ្តល់អំណាចក្នុងការសម្រេចចិត្ត ការទទួលផលដោយផ្ទាល់ពីទេសចរណ៍ប្រកបដោយសមធម៌ បង្កើននូវកម្រិតជីវភាព ចូលរួមដល់ការកាត់បន្ថយភាពក្រីក្រ និងការកាត់បន្ថយចំណាកស្រុករបស់ប្រជាជនមូលដ្ឋានប្រកបដោយប្រសិទ្ធភាព។ ផលប្រយោជន៍ដែលបានមកពីធម្មជាតិ តាមរយៈវិស័យទេសចរណ៍នឹងលើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានក្នុងការចូលរួមការពារ អភិរក្សធនធានធម្មជាតិ និងបរិស្ថានជុំវិញខ្លួន។
- **គំរូអភិវឌ្ឍអេកូទេសចរណ៍ខ្នាតធំ(ដោយផ្អែកលើវិនិយោគឯកជន)** : ជាយន្តការមួយដែលសមស្របក្នុងការអភិវឌ្ឍនៅតាមតំបន់ធម្មជាតិ(ពុំសូវមានវត្តមាននៃការតាំងទីលំនៅរបស់ប្រជាជនមូលដ្ឋាន) តម្រូវឱ្យមានការអភិវឌ្ឍអេកូទេសចរណ៍ខ្នាតធំដោយផ្អែកលើវិនិយោគឯកជនធំៗ ដោយប្រើប្រាស់ទុនវិនិយោគច្រើន។ ប៉ុន្តែការវិនិយោគនេះត្រូវប្រើប្រាស់នូវបច្ចេកវិទ្យាចុងក្រោយ ដែលឆ្លើយតបទៅនឹងកិច្ចការពារបរិស្ថាននិងសង្គមយ៉ាងច្បាស់លាស់។ ជានយោបាយ **គឺមិនតម្រូវឱ្យមានការជម្លៀសប្រជាជនមូលដ្ឋានដើមកំណើតនៅក្នុងគម្រោងអភិវឌ្ឍន៍ឡើយ។**

គោលដៅរួមជាយុទ្ធសាស្ត្ររបស់គោលនយោបាយជាតិអេកូទេសចរណ៍ ២០១៩-២០៣០ គឺ ១)-បង្កើនលទ្ធភាពអាជីវកម្មនិងវិនិយោគក្នុងរមណីយដ្ឋានអេកូទេសចរ ក្រោមសុខដុមនីយកម្មជាមួយសហគមន៍មូលដ្ឋាន ២)-បង្កើតប្រភពធនធានហិរញ្ញវត្ថុទ្រទ្រង់ការអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ និងសម្បទាទ្រទ្រង់ការអភិវឌ្ឍអេកូ-ទេសចរណ៍នៅកម្ពុជា ដើម្បីត្រៀមទាក់ទាញភ្ញៀវទេសចរណ៍អន្តរជាតិមកទស្សនាគោលដៅអេកូទេសចរណ៍ឱ្យបាន **៣លាននាក់នៅឆ្នាំ២០២០ ៤លាននាក់នៅឆ្នាំ២០២៥** និង**៦លាននាក់នៅឆ្នាំ២០៣០** អមជាមួយភ្ញៀវទេសចរជាតិទៅកាន់តំបន់អេកូទេសចរណ៍ឱ្យបាន**១០លាននាក់នៅឆ្នាំ២០៣០** ៣)-បង្កើតប្រភពធនធានហិរញ្ញវត្ថុសម្រាប់ចូលរួមទ្រទ្រង់ការអភិរក្សធនធានធម្មជាតិជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីនិងការការពារបរិស្ថាន ព្រមទាំងចូលរួមចំណែកដល់ការទប់ទល់នឹងបញ្ហាបម្រែបម្រួលអាកាសធាតុតាមរយៈការអភិវឌ្ឍអេកូទេសចរណ៍ ៤)-ចូលរួមលើកទឹកចិត្តឱ្យប្រជាពលរដ្ឋមូលដ្ឋានមានមោទនភាពក្នុងការអភិវឌ្ឍនិងអភិរក្សទំនៀមទម្លាប់ប្រពៃណីវប្បធម៌និងធនធានធម្មជាតិ ៥)-ចង្អុលបង្ហាញនូវគោលដៅណែនាំសម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីធានាបាននូវការសម្របសម្រួលមួយប្រកបដោយប្រសិទ្ធភាពខ្ពស់ និងការបង្កើនការយល់ដឹងក្នុងផ្នែកអេកូទេសចរណ៍ស្របតាមស្មារតីនៃច្បាប់ស្តីពីទេសចរណ៍ដែលបានបញ្ជាក់ថា អេកូទេសចរណ៍គឺជាការទទួលខុសត្រូវរួមគ្នារវាងក្រសួងទេសចរណ៍និងក្រសួងស្ថាប័នពាក់ព័ន្ធដទៃទៀត ៦)- រៀបចំនិងពង្រឹងយន្តការបទដ្ឋានគតិយុត្ត ដើម្បីធានាឱ្យរាល់សកម្មភាពអភិវឌ្ឍនិងការវិនិយោគក្នុងតំបន់អេកូទេសចរណ៍ ពិសេស ការអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ឬសកម្មភាពអេកូទេសចរណ៍នៅក្នុងតំបន់ការពារធម្មជាតិ តំបន់ព្រៃការពារ និងតំបន់ដីសម្បទាន គោរពតាមគោលការណ៍និរន្តរភាព។

ការដាក់ចេញគោលនយោបាយនេះ គឺជាការងារសំខាន់ ប៉ុន្តែការប្រែក្លាយគោលនយោបាយនេះឱ្យទៅជាសកម្មភាពនិងផ្ដល់ផលជាក់ស្ដែង តាមរយៈការរៀបចំឱ្យមានផែនការសកម្មភាព និងការអនុវត្តផែនការនេះគឺជាកត្តាចាំបាច់មិនអាចខ្វះបានដើម្បីធ្វើឱ្យសម្រេចបានគោលដៅចុងក្រោយរបស់យើង គឺការធ្វើឱ្យប្រសើរឡើងវិញនូវប្រសិទ្ធភាពនៃកិច្ចអភិរក្សធនធានធម្មជាតិ និងការកាត់បន្ថយភាពក្រីក្រដល់ប្រជាសហគមន៍ តាមរយៈវិស័យអេកូទេសចរណ៍ និងក៏ដូចជាការបង្កើនឧត្តមភាពប្រកួតប្រជែងដល់វិស័យទេសចរណ៍កម្ពុជា។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលប្ដេជ្ញាចិត្តផ្ដល់ការគាំទ្រដែលចាំបាច់ និងបង្កលក្ខណៈគាំទ្រគ្រប់បែបយ៉ាង ទាំងផ្នែកគោលនយោបាយនិងកម្មវិធីអភិវឌ្ឍនានា ដើម្បីអនុវត្តគោលនយោបាយនេះឱ្យបានជោគជ័យ។ ដោយសារវិស័យអេកូទេសចរណ៍មានចរិតអន្តរវិស័យ ការអនុវត្តគោលនយោបាយនេះទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់រួមមានទាំងវិស័យសាធារណៈ ប្រជាពលរដ្ឋ និងសហគមន៍មូលដ្ឋាន ក៏ដូចជាសង្គមស៊ីវិល និងដៃគូអភិវឌ្ឍ ដោយយើងត្រូវមានការខិតខំប្រឹងប្រែងរួមគ្នាឱ្យអស់លទ្ធភាព និងការប្ដេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ធ្វើឱ្យគោលដៅរួមរបស់យើងក្លាយជាការពិត ដើម្បីកម្ពុជាអាចសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។

ក្នុងន័យនេះ ខ្ញុំសូមស្នើគ្រប់ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ត្រូវផ្ដល់អាទិភាពដល់ការអនុវត្តជាក់ស្ដែងនូវគោលនយោបាយនេះ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់ "**វិស័យទេសចរណ៍ជាមាសបៃតង**" យ៉ាងពិតប្រាកដ និងជាវិស័យដែលចូលរួមដល់ការសម្រេចនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។

ដើម្បីឈានឆ្ពោះទៅគោលដៅនេះ រាជរដ្ឋាភិបាលតាមរយៈក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងារអន្តរក្រសួងគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ នឹងធានាឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនៅក្នុងដំណើរការនៃការអនុវត្តគោលនយោបាយជាតិអេកូទេសចរណ៍ ២០១៩-២០៣០ ជាមួយនិងក្រសួងស្ថាប័ននិងភាគីពាក់ព័ន្ធទាំងអស់។

ថ្ងៃ ពុធ ៤រោច ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ៩ ឆ្នាំ២០១៨

**ហ៊ុន សែន**

## ១- សេចក្តីផ្តើម

(១). ក្រោមការដឹកនាំដ៏ឈ្លាសវៃនិងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កម្ពុជាបច្ចុប្បន្នមានសុខសន្តិភាព ស្ថិរភាពសង្គម សន្តិសុខ សណ្តាប់ធ្នាប់ពេញលេញ ហើយគ្រប់វិស័យមានការរីកចម្រើន ក្នុងនោះវិស័យទេសចរណ៍កម្ពុជាដែលជា **"ទេសចរណ៍វប្បធម៌ និងធម្មជាតិ"** មានការរីកចម្រើនគួរឱ្យកត់សំគាល់។

(២). រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវិស័យទេសចរណ៍ ជាវិស័យអាទិភាពមួយដើរតួជា **"មាសបៃតង"** រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម តាមរយៈការបង្កើតនិងបង្កើនឱកាសការងារ បង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋដោយផ្ទាល់និងដោយប្រយោល លើកកម្ពស់ជីវភាពរស់នៅ ជំរុញការនាំចេញនៅនឹងកន្លែង ជំរុញកំណើនសេដ្ឋកិច្ច បង្កើនចំណូលជាតិ ចូលរួមដល់ការកាត់បន្ថយភាពក្រីក្រ ពិសេស ចូលរួមដល់ការឆ្លើយតបនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ ដែលជាបញ្ហាប្រឈមជាសកល។

(៣). ជាការពិត ទន្ទឹមនឹងកត្តាសន្តិសុខ សុវត្ថិភាព ស្ថិរភាពសង្គម សណ្តាប់ធ្នាប់ជាកត្តាគន្លឹះក្នុងការជំរុញការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជា សក្តានុពលដ៏សម្បូរបែបនៃសម្បត្តិធនធានវប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិក៏ជាកត្តាកំណត់ចូលរួមលើកកម្ពស់ **ឧត្តមភាពប្រៀបធៀបនៃវិស័យទេសចរណ៍កម្ពុជា** ទាំងនៅថ្នាក់តំបន់ ទាំងនៅសកលលោកផងដែរ។ ជាក់ស្តែង កម្ពុជាត្រូវបានសម្លឹងមើលឃើញថាសម្បូរទៅដោយធនធានធម្មជាតិនិងជីវៈចម្រុះដ៏សំបូរបែបពិសេស ប្រមូលផ្តុំនៅតាម **តំបន់ការពារធម្មជាតិចំនួន៥៧កន្លែង ស្មើនឹងផ្ទៃដី៧ ៤៣៩ ៦៥៩ហិចតា(ឧទ្យានជាតិចំនួន១២កន្លែង ដែនជម្រកសត្វព្រៃ១៨កន្លែង តំបន់ការពារទេសភាព១១កន្លែង តំបន់ប្រើប្រាស់ច្រើនយ៉ាង៧កន្លែង និងតំបន់វាលភក់ចំនួន៤កន្លែង តំបន់បេតិកភណ្ឌធម្មជាតិចំនួន២កន្លែង និងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិចំនួន៣កន្លែង)** តំបន់ការពារព្រៃឈើចំនួន **៩កន្លែង** ព្រៃកោងកាង ដែលផ្សារភ្ជាប់ជាមួយនឹងការតភ្ជាប់ទៅនឹងអ័ក្សអេកូឡូស៊ីដ៏ធំនៅលើពិភពលោកគឺព្រៃត្រូពិចជួរភ្នំក្រវាញ ដែលមានវិសាលភាពដ៏ធំធេង និងសម្បូរទៅដោយពពួកសត្វកម្រចុងក្រោយនៅតំបន់អាស៊ី ហើយបច្ចុប្បន្នតំបន់នេះត្រូវបានដាក់បញ្ចូលទៅក្នុងតំបន់អេកូទេសចរណ៍ល្បីៗទាំង១០នៅក្នុងពិភពលោក។ រីឯតំបន់ឆ្នេរសមុទ្រកម្ពុជាដែលលាតសន្ធឹងលើប្រវែង **៤៤០គីឡូម៉ែត្រ** បានក្លាយជាសមាជិក **ក្លឹបឆ្នេរសមុទ្រដែលស្អាតជាងគេបំផុតលើសកលលោក** តាំងពីឆ្នាំ២០១១មក ហើយសំបូរទៅដោយរុក្ខជាតិ សត្វសមុទ្រ និងជីវៈចម្រុះជាច្រើនដែលមានប្រមាណ៣០ប្រភេទ ពិសេស ព្រៃកោងកាងធំជាងគេនៅអាស៊ីអាគ្នេយ៍ គ្របដណ្តប់លើផ្ទៃដី **៥០ ០០០ហិចតា** និងផ្កាថ្ម **៧០ប្រភេទ** ស្ថិតក្នុង **៣៣ពួក** និង **១១អំបូរ**។ លើសពីនេះទៀត តំបន់ភាគឦសានក៏មានសក្តានុពលយ៉ាងធំធេងជាមួយនឹងតំបន់ខ្ពង់រាប ឧទ្យានជាតិ ទេសភាពទន្លេមេគង្គ សមុទ្រព្រៃឈើ ទឹកជ្រោះ សត្វផ្សោតទន្លេមេគង្គ ពពួកសត្វកម្រ និងជីវៈចម្រុះផ្សេងៗទៀត ពិសេសសហគមន៍ជនជាតិភាគតិចថែមទៀតផង។ ក្នុងន័យនេះ ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ ពិសេស អេកូទេសចរណ៍ដែលជាទម្រង់មួយនៃទេសចរណ៍ប្រកបដោយនិរន្តរភាព និងផ្តល់ផលចំណេញដល់សេដ្ឋកិច្ច-សង្គម ចូលរួមដល់កិច្ចគាំពារបរិស្ថានប្រកបដោយប្រសិទ្ធភាព ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកតម្កើងឧត្តមភាពប្រៀបធៀបនៃវិស័យទេសចរណ៍កម្ពុជា។

(៤). អេកូទេសចរណ៍ត្រូវបានមើលឃើញថា បានចូលរួមដល់កិច្ចការពារបរិស្ថានប្រកបដោយប្រសិទ្ធភាព ខណៈដែលតំបន់អាស៊ីអាគ្នេយ៍រំពឹងថានឹងក្លាយទៅជាគោលដៅអេកូទេសចរណ៍ដ៏ធំជាងគេនៅលើសកលលោក នាថ្ងៃអនាគត ហើយកម្ពុជាក៏ត្រូវបានវាយតម្លៃជាគោលដៅអេកូទេសចរណ៍អាទិភាពមួយក្នុងតំបន់នេះដែរ។ នៅ

កម្រិតសកលលោក និន្នាការអេកូទេសចរណ៍ជានិន្នាការងើបឡើងថ្មី ដែលមានតម្រូវការខ្ពស់ ហើយក្នុងសតវត្ស ទី២១នេះ អង្គការទេសចរណ៍ពិភពលោកបានព្យាករថា និន្នាការអេកូទេសចរណ៍អាចមានកំណើនដល់**២០%** ជារៀងរាល់ឆ្នាំ ក្នុងពេលដែលប្រភេទទេសចរណ៍ទូទៅអាចមានកំណើនជាមធ្យមត្រឹមតែ**៦%** ប៉ុណ្ណោះក្នុងមួយឆ្នាំៗ។

(**៥**). រហូតមកដល់បច្ចុប្បន្ននេះ ក្រសួងទេសចរណ៍ក្រោមកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ពិសេសក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គការជាតិអន្តរជាតិនានា បានរៀបចំឲ្យមានសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ចំនួន**៥៦កន្លែង** ដែលស្ថិតនៅក្នុងខេត្តចំនួន**១៦**ដែលក្នុងនោះសហគមន៍ទេសចរណ៍បែបអេកូទេសចរណ៍ចំនួន**៥០** និងបែបវប្បធម៌ចំនួន**២** បែបវប្បធម៌ធម្មជាតិចំនួន**២** បែបវប្បធម៌ប្រវត្តិសាស្ត្រចំនួន**១** និងបែបកែច្នៃចំនួន**១**។

(**៦**). នយោបាយអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព ក៏បានឆ្លុះបញ្ចាំងឲ្យឃើញថា **ការអភិវឌ្ឍអេកូទេសចរណ៍និងសហគមន៍ទេសចរណ៍** គឺជាយន្តការមួយដ៏សមស្របសម្រាប់ការអភិវឌ្ឍនិងអភិរក្សក្នុងតំបន់ការពារធម្មជាតិ ប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធភាព និងផ្តល់ឱកាសឲ្យប្រជាពលរដ្ឋមូលដ្ឋានអាចចូលរួមយ៉ាងសកម្មក្នុងការសម្រេចចិត្តឬអាចនិយាយបានថា ជាការផ្តល់នូវ**សិទ្ធិអំណាចដល់ប្រជាពលរដ្ឋមូលដ្ឋាន** (Local Empowerment) ដោយប្រជាពលរដ្ឋអាចទទួលផលប្រយោជន៍ដោយផ្ទាល់ពីទេសចរណ៍ប្រកបដោយសមធម៌ ចូលរួមក្នុងការសម្រេចចិត្តអភិវឌ្ឍមូលដ្ឋានខ្លួន បង្កើននូវកម្រិតជីវភាព និងចូលរួមដល់ការកាត់បន្ថយភាពក្រីក្ររបស់ពួកគាត់ និងចំណាកស្រុក ប្រកបដោយប្រសិទ្ធភាព។ ដូចនេះ ផលប្រយោជន៍ដែលបានមកពីធម្មជាតិ តាមរយៈវិស័យទេសចរណ៍ នឹងលើកទឹកចិត្តដល់ប្រជាពលរដ្ឋមូលដ្ឋានឲ្យចូលរួមការពារនិងអភិរក្សធនធានធម្មជាតិ និងបរិស្ថានជុំវិញខ្លួនថែមទៀត។

(**៧**). ជាឧទាហរណ៍ នៅ**សហគមន៍អេកូទេសចរណ៍ជីផាត**(**ឃុំជីផាត ស្រុកថ្មបាំង ខេត្តកោះកុង**) ជាមួយនឹងការបញ្ចូលសកម្មភាពទេសចរណ៍(អេកូទេសចរណ៍) ទៅក្នុងសហគមន៍មូលដ្ឋាន យើងសង្កេតឃើញថា ប្រជាសហគមន៍ចាប់ផ្តើមទទួលផលប្រយោជន៍សេដ្ឋកិច្ច ហើយឈប់ប្រកបអាជីវកម្មដែលបំផ្លាញធនធានធម្មជាតិដោយឈប់បរបាញ់សត្វ កាប់បំផ្លាញព្រៃឈើ និងងាកមកធ្វើជា**មគ្គុទ្ទេសក៍នាំភ្ញៀវ លក់ដូរម្ហូបអាហារ លក់វត្ថុអនុស្សាវរីយ៍ រត់ម៉ូតូដឹកភ្ញៀវ បើកផ្ទះស្នាក់** និងចូលរួមសកម្មភាពផ្សេងៗទៀតដែលបម្រើដល់ការអភិវឌ្ឍវិស័យទេសចរណ៍/អេកូទេសចរណ៍ ព្រមទាំងចូលរួមធ្វើជាអ្នកល្បាតការពារ (Rangers) សម្បត្តិដ៏មានតម្លៃទាំងនេះថែមទៀតផង ដើម្បីធានាឲ្យមានការអភិវឌ្ឍយូរអង្វែង។ ជាលទ្ធផល ចំណូលដែលបានមកពីការផ្តល់សេវាផ្សេងៗ (ដូចជាផ្ទះស្នាក់ ផ្ទះសំណាក់ សេវាម៉ូតូដឹកភ្ញៀវ ម្ហូបអាហារ សេវាទូក សេវារទេះគោ/ក្របី និងការជួលសម្ភារៈផ្សេងៗ) គឺត្រូវទទួលផលដោយផ្ទាល់ ដោយអ្នកផ្តល់សេវាតែម្តង **ហើយបានច្រើនជាងចំណូលដែលបានពីការបាញ់សត្វឬកាប់ឈើដល់ទៅ២ដង**)។ មូលនិធិសហគមន៍នេះត្រូវបានយកទៅប្រើប្រាស់ក្នុងគោលបំណងច្រើនយ៉ាង ដូចជាឧបត្ថម្ភដល់សមាជិកគណៈកម្មាធិការគ្រប់គ្រងសហគមន៍ ការចំណាយចរន្តរបស់គម្រោង ការថែទាំ និងជួសជុលសម្ភារៈបម្រើដល់សកម្មភាពអេកូទេសចរណ៍ ឧបត្ថម្ភអ្នកល្បាតសហគមន៍ ការអភិវឌ្ឍផលិតផលទេសចរណ៍ថ្មីៗបន្ថែមទៀត មូលនិធិសង្គម និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍។ ដោយឡែក ដោយយល់ពីសារៈសំខាន់នៃធនធានធម្មជាតិ **អ្នកប្រមាញ់និងអ្នកកាប់ឈើ១០០% (៨០នាក់)** បានលះបង់សកម្មភាពបាញ់សត្វ កាប់ឈើរបស់ខ្លួន ហើយងាកមកចូលរួមក្នុងសកម្មភាពអេកូទេសចរណ៍សហគមន៍ និងចូលរួមដល់ការការពារសម្បត្តិធនធានដ៏មានតម្លៃទាំងនេះ ដើម្បីទទួលផលបានយូរអង្វែងសម្រាប់ខ្លួននាពេលបច្ចុប្បន្ន និងសម្រាប់កូនចៅជំនាន់ក្រោយទៅអនាគត។

ថែមទៀតផង។ សហគមន៍នេះបានអភិវឌ្ឍនូវធនធានមនុស្សរបស់ខ្លួន និងបានចូលរួមចំណែកក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធតូចៗ ក្នុងសហគមន៍ជាបន្តបន្ទាប់ (អ្នកបរបាញ់សត្វម្នាក់ត្រូវបានសហគមន៍បោះឆ្នោតឲ្យធ្វើជាប្រធានសហគមន៍)។

(**៨**). ដោយឡែក នៅសហគមន៍អេកូទេសចរណ៍អន្លង់ផ្សោតកាំពី បានបង្កើតឡើងក្នុងឆ្នាំ១៩៩៩ ក្រោមកិច្ចសហការគាំទ្រពីអង្គការទេសចរណ៍ពិភពលោក(UNWTO) បានអភិវឌ្ឍតំបន់នេះក្លាយជាគោលដៅទេសចរណ៍បែបអេកូទេសចរណ៍ប្រកបដោយភាពទាក់ទាញ ហើយបានផ្ដល់ផលប្រយោជន៍ដោយផ្ទាល់ពីវិស័យទេសចរណ៍ដល់ប្រជាសហគមន៍ចំនួន**១៦០គ្រួសារ** តាមរយៈការបង្កើតនូវមុខរបរសិប្បកម្មចម្លាក់បម្រើឲ្យភ្ញៀវទេសចរ រៀបចំផ្ទះស្នាក់ សេវាដឹកជញ្ជូនភ្ញៀវ សេវាម្ហូបអាហារជូនភ្ញៀវទេសចរ ហើយជីវភាពរបស់ប្រជាពលរដ្ឋមានភាពប្រសើរជាងមុន។ រីឯការយកចិត្តទុកដាក់ថែរក្សានិងអភិរក្សសត្វផ្សោតដោយសហគមន៍កាន់តែមានប្រសិទ្ធភាពខ្ពស់ ដោយប្រជាពលរដ្ឋដែលធ្លាប់ប្រកបមុខរបរនេសាទ(ដែលធ្វើឲ្យប៉ះពាល់ដល់ជីវិតសត្វផ្សោត) បានងាកមកប្រកបមុខរបរផ្ដល់សេវាកម្មឲ្យភ្ញៀវទេសចរវិញ។

(**៩**). ជាការពិត ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍអេកូទេសចរណ៍និងសហគមន៍ទេសចរណ៍ឱ្យមាននិរន្តរភាព រាជរដ្ឋាភិបាលដែលមានក្រសួងទេសចរណ៍ជាសេនាធិការ សហការជាមួយក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងស្ថាប័នពាក់ព័ន្ធ សហគមន៍មូលដ្ឋាន និងដៃគូអភិវឌ្ឍ ក៏បានរៀបចំបង្កើតសេវាកម្មទេសចរណ៍ថ្មីៗ ដូចជាការបង្កើតមគ្គុទ្ទេសក៏សហគមន៍ ការបង្កើតផ្ទះស្នាក់នៅក្នុងសហគមន៍ ការរៀបចំឲ្យមានកញ្ចប់ទស្សនកិច្ច (Eco-tours) ជាប្រចាំរបស់ភ្ញៀវទេសចរទៅកាន់តំបន់អេកូទេសចរណ៍ឬសហគមន៍ទេសចរណ៍នានាក្នុងតំបន់ការពារធម្មជាតិ និងរៀបចំកម្មវិធីដាំដើមឈើរបស់ភ្ញៀវទេសចរ ក្រោមពាក្យស្លោក **"ទេសចរម្នាក់ ដើមឈើមួយដើម"**។ល។

(**១០**). ទន្ទឹមនឹងនេះ ចំពោះមុខ ដើម្បីដោះស្រាយនូវបញ្ហាប្រឈមនានារបស់ប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន (ជាអាទិ៍ កង្វះទុនវិនិយោគ កង្វះបច្ចេកទេស កង្វះឱកាសទីផ្សារ សមត្ថភាពជំនាញមានកម្រិត ...) និងដើម្បីចាប់យកកាលានុវត្តភាពពីសក្ដានុពលនៃធនធានធម្មជាតិរបស់កម្ពុជា ក៏ដូចជាដើម្បីប្រែក្លាយឲ្យតំបន់ការពារធម្មជាតិក្លាយជា**ផលិតផលទេសចរណ៍ ប្រកបដោយភាពច្នៃប្រឌិត និងនវានុវត្តភាព (Creative & Innovative)** ចូលរួមដល់ការអភិវឌ្ឍវិស័យទេសចរណ៍ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងកិច្ចគាំពារធនធានធម្មជាតិ រាជរដ្ឋាភិបាលកម្ពុជាសម្រេចដាក់ចេញនូវគោលនយោបាយជាតិអេកូទេសចរណ៍ សំដៅដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រគន្លឹះនានាដើម្បីកែច្នៃតំបន់ការពារធម្មជាតិឱ្យក្លាយជាគោលដៅទេសចរណ៍ដ៏ទាក់ទាញ និងបានជាប្រយោជន៍ដល់ប្រជាពលរដ្ឋមូលដ្ឋាន ប្រកបដោយសមធម៌ និងដោះស្រាយនូវបញ្ហាគន្លឹះមួយចំនួន ដែលកើតមានរវាងផ្នែកសាធារណៈ ក្រុមហ៊ុនឯកជន និងប្រជាពលរដ្ឋមូលដ្ឋាន ពោលគឺដាក់ចេញនូវគំរូ(Model) សម្រាប់កិច្ចសហការ (4Ps : Public-Private-People-Partnership) ពីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ រាប់ទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់(ផ្លូវចូល សម្បទាទេសចរណ៍) ការរៀបចំសេវាទេសចរណ៍ ការបណ្ដុះបណ្ដាលជំនាញ ការបង្កើតមុខរបរពាក់ព័ន្ធដល់ប្រជាពលរដ្ឋមូលដ្ឋាន ការស្វែងរកទីផ្សារសម្រាប់សហគមន៍ និងជាពិសេស គំរូស្វែងរកទុន(ធនធានហិរញ្ញវត្ថុ) សម្រាប់ឲ្យសហគមន៍មូលដ្ឋានអាចវិនិយោគនិងអភិវឌ្ឍសេវាកម្មបម្រើឲ្យភ្ញៀវទេសចរបាន។

(**១១**). ដូច្នេះ ការរៀបចំគោលនយោបាយជាតិអេកូទេសចរណ៍ត្រូវផ្អែកលើច្បាប់ស្ដីពីទេសចរណ៍ គោលនយោបាយជាតិទេសចរណ៍ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល និងឯកសារច្បាប់បទដ្ឋានគតិយុត្តនានាព្រមទាំងសេចក្ដីប្រកាសទីក្រុងកេបិចស្ដីពីការអភិវឌ្ឍអេកូទេសចរណ៍ឆ្នាំ២០០២ សេចក្ដីប្រកាសក្រុងសៀមរាបនូវ

ស្តីពីការអភិវឌ្ឍអេកូទេសចរណ៍ឆ្នាំ២០០៩ សេចក្តីប្រកាសក្រុងព្រះសីហនុស្តីពីកិច្ចសហប្រត្តិបត្តិការពហុភាគីដើម្បីការអភិវឌ្ឍអេកូទេសចរណ៍ឆ្នាំ២០១១ សេចក្តីប្រកាសក្រុងភ្នំពេញស្តីពីការអភិវឌ្ឍសហគមន៍តាមរយៈវិស័យទេសចរណ៍ឆ្នាំ២០១៤ សម្រាប់ធានាឱ្យមានការចូលរួមប្រកបដោយភាពសុខដុមរវាងគ្រប់ភាគី និងវិស័យពាក់ព័ន្ធ អមដោយយន្តការប្រកបដោយប្រសិទ្ធភាពនិងសក្តិសិទ្ធភាពលើការទាញយកផលប្រយោជន៍ជាអតិបរមានៃការអភិវឌ្ឍអេកូទេសចរណ៍ ចូលរួមដល់ការសម្រេចបាននូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល។

**២- ចក្ខុវិស័យ**

(១២). ចក្ខុវិស័យនៃគោលនយោបាយអេកូទេសចរណ៍ សំដៅធ្វើឱ្យប្រទេសកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព និងជាគោលដៅអេកូទេសចរណ៍ដ៏ទាក់ទាញថ្មីមួយប្រកបដោយភាពប្រកួតប្រជែងខ្ពស់នៅក្នុងតំបន់និងសកលលោក តាមរយៈការបង្កើតនូវផលិតផលអេកូទេសចរណ៍ ដែលអាចផ្តល់នូវបទពិសោធល្អៗប្រកបដោយគុណភាពខ្ពស់ជិតជាប់អារម្មណ៍ភ្ញៀវទេសចរ ដើម្បីចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងជំរុញកិច្ចអភិរក្សធនធានធម្មជាតិ រួមចំណែកទប់ទល់បម្រែបម្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព។

**៣- គោលបំណងនិងគោលដៅ**

(១៣). ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ គោលនយោបាយជាតិនេះ បានកំណត់នូវគោលបំណង ដូចខាងក្រោម៖

**៣.១- គោលបំណង**

(១៤). គោលនយោបាយជាតិនេះមានគោលបំណង៖

- ធ្វើពិពិធកម្មផលិតផលទេសចរណ៍ពីតំបន់ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ ទៅតំបន់អេកូទេសចរណ៍
- លើកតម្កើងកិត្យានុភាពកម្ពុជាជាគោលដៅអេកូទេសចរណ៍ដ៏លេចធ្លោមួយនៅតំបន់អាស៊ីអាគ្នេយ៍
- លើកកម្ពស់ទីផ្សារអេកូទេសចរណ៍ដែលកំពុងតែមានកំណើនខ្ពស់នៅកម្ពុជា តាមរយៈការអភិវឌ្ឍផលិតផលទេសចរណ៍ ប្រកបដោយភាពច្នៃប្រឌិត និវានុវត្តភាព និងគុណភាព
- លើកទឹកចិត្តនិងជំរុញឱ្យវិស័យឯកជននិងដៃគូអភិវឌ្ឍនានាយកចិត្តទុកដាក់លើការអភិវឌ្ឍអេកូសចរណ៍ តាមរយៈការគាំទ្រហិរញ្ញប្បទាន និងការពង្រឹងសមត្ថភាពដល់អ្នកពាក់ព័ន្ធក្នុងគម្រោងអភិវឌ្ឍអេកូ-ទេសចរណ៍
- លើកទឹកចិត្តសហគមន៍និងប្រជាពលរដ្ឋមូលដ្ឋានក្នុងកិច្ចអភិរក្សធនធានធម្មជាតិ និងការការពារបរិស្ថាន តាមរយៈការផ្តល់ប្រភពចំណូលថ្មី ពីសកម្មភាពអេកូទេសចរណ៍ និងផ្តល់សិទ្ធិអំណាចដល់សហគមន៍ក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍសកម្មភាពអេកូទេសចរណ៍
- លើកកម្ពស់អភិបាលកិច្ចក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍអេកូទេសចរណ៍នៅកម្ពុជា។

**៣.២- គោលដៅ**

(១៥). ដើម្បីសម្រេចបានគោលបំណងខាងលើនេះ គោលនយោបាយជាតិនេះ មានគោលដៅដូចខាងក្រោម៖

- បង្កើនលទ្ធភាពធ្វើអាជីវកម្មនិងវិនិយោគក្នុងរមណីយដ្ឋានអេកូទេសចរណ៍ ក្រោមសុខដុមនីយកម្មជាមួយសហគមន៍មូលដ្ឋាន

- បង្កើតប្រភពធនធានហិរញ្ញវត្ថុ ទ្រទ្រង់ការអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ និងសម្បទាទ្រទ្រង់ការអភិវឌ្ឍអេកូទេសចរណ៍នៅកម្ពុជា ដើម្បីត្រៀមទាក់ទាញភ្ញៀវទេសចរអន្តរជាតិឱ្យមកទស្សនាគោលដៅអេកូទេសចរណ៍ឱ្យបាន**៣លាននាក់**នៅឆ្នាំ២០២០ **៤លាននាក់**នៅឆ្នាំ២០២៥ និង**៦លាននាក់**នៅឆ្នាំ២០៣០ អមជាមួយភ្ញៀវទេសចរជាតិដែលទៅកាន់តំបន់អេកូទេសចរណ៍ឱ្យបាន**១០លាននាក់**នៅឆ្នាំ២០៣០។
- បង្កើតប្រភពធនធានហិរញ្ញវត្ថុសម្រាប់ចូលរួមទ្រទ្រង់ការអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី និងការការពារបរិស្ថាន ព្រមទាំងចូលរួមចំណែកដល់ការទប់ទល់នឹងបញ្ហាបម្រែបម្រួលអាកាសធាតុ តាមរយៈការអភិវឌ្ឍអេកូទេសចរណ៍
- ចូលរួមលើកទឹកចិត្តឱ្យប្រជាពលរដ្ឋមូលដ្ឋានមានមោទនភាពក្នុងការអភិវឌ្ឍនិងអភិរក្សទំនៀមទម្លាប់ប្រពៃណីវប្បធម៌ និងធនធានធម្មជាតិ
- ចង្អុលបង្ហាញនូវគោលការណ៍ណែនាំសម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីធានាបាននូវការសម្របសម្រួលមួយប្រកបដោយប្រសិទ្ធភាពខ្ពស់ និងការបង្កើនការយល់ដឹងក្នុងផ្នែកអេកូទេសចរណ៍ស្របតាមស្មារតីនៃច្បាប់ស្តីពីទេសចរណ៍ ដែលបានគូសបញ្ជាក់ថា**អេកូទេសចរណ៍គឺជាការទទួលខុសត្រូវរួមគ្នា**រវាងក្រសួងទេសចរណ៍និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត
- រៀបចំនិងពង្រឹងយន្តការនិងបទដ្ឋានគតិយុត្ត ដើម្បីធានាឱ្យរាល់សកម្មភាពអភិវឌ្ឍនិងការវិនិយោគក្នុងតំបន់អេកូទេសចរណ៍ ពិសេស ការអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ឬសកម្មភាពអេកូទេសចរណ៍នៅក្នុងតំបន់ការពារធម្មជាតិ តំបន់ព្រៃការពារ និងតំបន់ដីសម្បទាន គោរពតាមគោលការណ៍និរន្តរភាព។

**(១៦).** ដើម្បីសម្រេចបាននូវគោលបំណងនិងគោលដៅខាងលើ ការអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍នៅព្រះរាជាណាចក្រកម្ពុជាត្រូវផ្អែកលើ**គំរូ២ ជាមូលដ្ឋាន៖**

❖ **គំរូអភិវឌ្ឍអេកូទេសចរណ៍ខ្នាតតូច(ដោយផ្អែកលើសហគមន៍មូលដ្ឋាន)** : ជាយន្តការមួយដ៏សមស្របសម្រាប់ការអភិវឌ្ឍក្នុងតំបន់ធម្មជាតិមួយដែលមានប្រជាពលរដ្ឋមូលដ្ឋានរស់នៅផ្សារភ្ជាប់ទៅនឹងធម្មជាតិក្នុងកម្រិតអតិបរមា ដែលការអភិវឌ្ឍនេះនឹងធ្វើឱ្យគ្រប់ភាគីពាក់ព័ន្ធ ពិសេស ប្រជាពលរដ្ឋមូលដ្ឋានអាចចូលរួមយ៉ាងសកម្មតាមរយៈការផ្តល់អំណាចក្នុងការសម្រេចចិត្ត ទទួលផលដោយផ្ទាល់ពីទេសចរណ៍ប្រកបដោយសមធម៌ បង្កើននូវកម្រិតជីវភាព ចូលរួមដល់ការកាត់បន្ថយភាពក្រីក្រនិងការកាត់បន្ថយចំណាកស្រុករបស់ប្រជាជនមូលដ្ឋានប្រកបដោយប្រសិទ្ធភាព។ ផលប្រយោជន៍ដែលបានមកពីធម្មជាតិតាមរយៈវិស័យទេសចរណ៍នឹងលើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានក្នុងការចូលរួមការពារ អភិរក្សធនធានធម្មជាតិនិងបរិស្ថានជុំវិញខ្លួន។

❖ **គំរូអភិវឌ្ឍអេកូទេសចរណ៍ខ្នាតតូច**អាចត្រូវបានអនុវត្តតាមទម្រង់នៃជម្រើសជាយុទ្ធសាស្ត្រ ដូចខាងក្រោម៖

- ***ភាពជាម្ចាស់របស់សហគមន*** : សហគមន៍ជាអ្នកផ្តួចផ្តើម អភិវឌ្ឍ និងគ្រប់គ្រងរាល់សម្បទា សេវាកម្ម និងសកម្មភាពអេកូទេសចរណ៍នៅក្នុងតំបន់សហគមន៍ផ្ទាល់និង/ឬផ្នែកណាមួយនៃតំបន់ការពារធម្មជាតិ តំបន់ព្រៃការពារ ដោយមានការអនុញ្ញាតនិងទទួលស្គាល់ដោយក្រុមការងារអន្តរក្រសួងគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍។
- ***ភាពជាដៃគូសហគមន៍-រដ្ឋ-ឯកជន*** : សហគមន៍ជាអ្នកផ្តួចផ្តើមនិងអភិវឌ្ឍសកម្មភាពអេកូទេសចរណ៍នៅក្នុងតំបន់សហគមន៍ផ្ទាល់និង/ឬផ្នែកណាមួយនៃតំបន់ការពារធម្មជាតិ តំបន់ព្រៃការពារ ឧទ្យានជាតិ

(សហគមន៍ជាអ្នកអភិវឌ្ឍ) ដោយមានការអនុញ្ញាតនិងទទួលស្គាល់ដោយក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍។ ដោយមានតម្រូវការមូលធននិងបច្ចេកទេស សហគមន៍ស្វែងរកការចូលរួមសហការពីផ្នែកឯកជនក្នុងការអនុវត្ត រៀបចំ និងគ្រប់គ្រងរាល់សម្បទា សេវាកម្ម និង/ឬសកម្មភាពអេកូទេសចរណ៍ ដោយផ្អែកលើកិច្ចសន្យាឬកិច្ចព្រមព្រៀងជាក់លាក់ណាមួយ ដោយមានការបញ្ជាក់ពីយន្តការក្នុងការអនុវត្តរួមគ្នា ការគ្រប់គ្រងរួមគ្នា ការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌ កិច្ចគាំពារបរិស្ថាន និងការអភិរក្សសម្បត្តិធនធានធម្មជាតិ។ល។ ក្នុងករណីនេះ ការវិនិយោគដោយផ្នែកឯកជនមិនមែនជាការជំនួសឱ្យសកម្មភាពអភិវឌ្ឍរបស់សហគមន៍មូលដ្ឋាននោះទេ តែវានឹងដើរតួជាសកម្មភាពបំពេញបន្ថែម ជាប្រយោជន៍សម្រាប់ការអភិវឌ្ឍមួយប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

- **ភាពជាដៃគូសហគមន៍-រដ្ឋ-ដៃគូអភិវឌ្ឍ** : សហគមន៍ជាអ្នកផ្តួចផ្តើមនិងអភិវឌ្ឍសកម្មភាពអេកូ-ទេសចរណ៍នៅក្នុងតំបន់សហគមន៍ផ្ទាល់និង/ឬផ្នែកណាមួយនៃតំបន់ការពារធម្មជាតិ តំបន់ព្រៃការពារឧទ្យានជាតិ(សហគមន៍ជាអ្នកអភិវឌ្ឍ) ដោយមានការអនុញ្ញាតនិងទទួលស្គាល់ដោយក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍។ ដោយមានតម្រូវការមូលធននិងបច្ចេកទេស សហគមន៍អាចស្វែងរកជំនួយសហការពីដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិក្នុងការអនុវត្តរៀបចំ និងគ្រប់គ្រងរាល់សម្បទា សេវាកម្ម និង/ឬសកម្មភាពអេកូទេសចរណ៍ ដោយផ្អែកលើកិច្ចព្រមព្រៀងជាក់លាក់ណាមួយ ដោយមានការបញ្ជាក់ពីយន្តការក្នុងការអនុវត្តរួមគ្នា ការគ្រប់គ្រងរួមគ្នា ការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌សម្រាប់សមាជិកសហគមន៍ កិច្ចគាំពារបរិស្ថាន និងការអភិរក្សសម្បត្តិធនធានធម្មជាតិ។ល។

❖ **គំរូអភិវឌ្ឍអេកូទេសចរណ៍ខ្នាតធំ(ដោយផ្អែកលើវិនិយោគឯកជន)** : ជាយន្តការមួយដែលសមស្របក្នុងការអភិវឌ្ឍនៅតាមតំបន់ធម្មជាតិ(ពុំសូវមានវត្តមាននៃការតាំងទីលំនៅរបស់ប្រជាជនមូលដ្ឋាន) តម្រូវឱ្យមានការអភិវឌ្ឍអេកូទេសចរណ៍ខ្នាតធំដោយផ្អែកលើវិនិយោគឯកជនធំៗ ដោយប្រើប្រាស់ទុនវិនិយោគច្រើន។ ប៉ុន្តែការវិនិយោគនេះត្រូវប្រើប្រាស់នូវបច្ចេកវិទ្យាចុងក្រោយ ដែលឆ្លើយតបទៅនឹងកិច្ចការពារបរិស្ថាននិងសង្គមយ៉ាងច្បាស់លាស់។ ជានយោបាយ **គឺមិនតម្រូវឱ្យមានការជម្លៀសប្រជាជនមូលដ្ឋានកំណើតនៅក្នុងគម្រោងអភិវឌ្ឍដីសម្បទានសេដ្ឋកិច្ចឡើយ។**

❖ **គំរូអភិវឌ្ឍអេកូទេសចរណ៍ខ្នាតធំអាចត្រូវបានអនុវត្តតាមទម្រង់នៃជម្រើសជាយុទ្ធសាស្ត្រដូចខាងក្រោម៖**

- **ភាពនាំមុខរបស់ផ្នែកឯកជន** : ផ្នែកឯកជនជាអ្នកផ្តួចផ្តើម អនុវត្ត និងគ្រប់គ្រងរាល់សម្បទាន សេវាកម្ម និងសកម្មភាពអេកូទេសចរណ៍នៅក្នុងតំបន់ធម្មជាតិណាមួយនិង/ឬផ្នែកណាមួយនៃតំបន់ការពារធម្មជាតិ តំបន់ព្រៃការពារ តំបន់ដីសម្បទានដោយមានការអនុញ្ញាតនិងទទួលស្គាល់ដោយរាជរដ្ឋាភិបាលតាមរយៈក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍។ ក្រុមហ៊ុនឯកជនជាអ្នកអភិវឌ្ឍរមណីយដ្ឋានមានកាតព្វកិច្ចចំពោះទំនួលខុសត្រូវសង្គមនិងបរិស្ថានយ៉ាងហ្មត់ចត់ ស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ពិសេស លើកិច្ចគាំពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ។ល។

- **ភាពជាដៃគូឯកជន-សហគមន៍-រដ្ឋ** : ផ្នែកឯកជនជាអ្នកផ្តួចផ្តើម អនុវត្តរៀបចំសម្បទា សេវាកម្ម និងសកម្មភាពអេកូទេសចរណ៍នៅក្នុងតំបន់ធម្មជាតិណាមួយនិង/ឬផ្នែកណាមួយនៃតំបន់ការពារធម្មជាតិ

តំបន់ព្រៃការពារ តំបន់ដីសម្បទានដោយមានការអនុញ្ញាត និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល តាមរយៈក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍។ ដោយមានលំនៅឋានរបស់សហគមន៍(កម្រិតតិចតួច)ស្ថិតនៅជុំវិញឬក្បែរទីតាំងនៃគម្រោងអភិវឌ្ឍ ផ្នែកឯកជនត្រូវផ្ដល់លទ្ធភាពឱ្យមានការចូលរួមពីសហគមន៍ក្នុងការរៀបចំផែនការ ការអនុវត្ត និងការទទួលបានផលពីការអភិវឌ្ឍសកម្មភាពអេកូទេសចរណ៍ តាមរយៈការផ្ដល់ការងារនិងការបែងចែកផលចំណេញក្នុងកម្រិតសមស្របមួយ ដោយផ្អែកលើកិច្ចសន្យាឬកិច្ចព្រមព្រៀងជាក់លាក់ណាមួយ។ ផ្នែកឯកជនជាអ្នកអភិវឌ្ឍមានកាតព្វកិច្ចចំពោះទំនួលខុសត្រូវផ្នែកសង្គមនិងបរិស្ថានយ៉ាងហ្មត់ចត់ ស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ពិសេស លើកិច្ចគាំពារបរិស្ថាននិងការអភិរក្សធនធានធម្មជាតិ។ល។

- ***ភាពជាដៃគូឯកជន-រដ្ឋ-ដៃគូអភិវឌ្ឍ*** : ផ្នែកឯកជនជាអ្នកផ្ដួចផ្ដើមអនុវត្តរៀបចំសម្បទា សេវាកម្ម និងសកម្មភាពអេកូទេសចរណ៍នៅក្នុងតំបន់ធម្មជាតិណាមួយនិង/ឬផ្នែកណាមួយនៃតំបន់ការពារធម្មជាតិ តំបន់ព្រៃការពារ តំបន់ដីសម្បទានដោយមានការអនុញ្ញាតនិងទទួលស្គាល់ដោយរាជរដ្ឋាភិបាល តាមរយៈក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍។ ដោយមានតម្រូវការជំនួយបច្ចេកទេស ផ្នែកឯកជនអាចស្វែងរកជំនួយសហការពីដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិក្នុងការរៀបចំនិងគ្រប់គ្រងសម្បទា សេវាកម្ម និង/ឬសកម្មភាពអេកូទេសចរណ៍ ដោយផ្អែកលើកិច្ចព្រមព្រៀងជាក់លាក់ណាមួយ។ ផ្នែកឯកជនជាអ្នកអភិវឌ្ឍមានកាតព្វកិច្ចចំពោះទំនួលខុសត្រូវផ្នែកសង្គមនិងបរិស្ថាន(CSR) យ៉ាងហ្មត់ចត់ ស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ពិសេស លើកិច្ចគាំពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ។ល។

(១៧). **គំរូទាំងពីរខាងលើនេះ**ត្រូវគោរពតាម**គោលការណ៍គ្រឹះ** ដូចខាងក្រោម៖

១- ផ្ដោតជាសំខាន់ទៅលើធនធានធម្មជាតិដែលមានភាពទាក់ទាញជាចម្បងសម្រាប់សកម្មភាពអេកូទេសចរណ៍។

២- កាត់បន្ថយឱ្យបានជាអតិបរមានូវរាល់ផលប៉ះពាល់ជាអវិជ្ជមានដែលអាចកើតចេញពីសកម្មភាពអេកូទេសចរណ៍ ពិសេស ទៅលើបរិស្ថាននិងសង្គម។

៣- បង្កើនការយល់ដឹងអំពីសារៈសំខាន់នៃធនធានធម្មជាតិនិងសម្បត្តិវប្បធម៌។

៤- ជំរុញការអភិវឌ្ឍដោយត្រូវធានាឱ្យបានការអភិវឌ្ឍអេកូទេសចរណ៍ចូលរួមដល់ការថែរក្សាអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះប្រព័ន្ធអេកូឡូស៊ី ប្រពៃណី ទំនៀមទម្លាប់ វប្បធម៌របស់ប្រជាជនមូលដ្ឋាន។

៥- ផ្ដល់នូវប្រភពចំណូលដល់ប្រជាជនមូលដ្ឋាន តាមរយៈការចូលរួមក្នុងសកម្មភាពអេកូទេសចរណ៍។

៦- ផ្ដល់សិទ្ធិអំណាចឱ្យសហគមន៍មូលដ្ឋាន តាមរយៈការលើកទឹកចិត្តឱ្យមានការចូលរួមនិងគ្រប់គ្រងដំណើរការអភិវឌ្ឍអេកូទេសចរណ៍។

៧- សម្របសម្រួលនិងជំរុញភាពជាដៃគូរវាងផ្នែកសាធារណៈ ផ្នែកឯកជន ប្រជាជនទេសចរ និងដៃគូអភិវឌ្ឍ (4P) ក្នុងការធ្វើផែនការ ការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃសកម្មភាពអេកូទេសចរណ៍។

## ៤- យុទ្ធសាស្ត្រអភិវឌ្ឍអេកូទេសចរណ៍កម្ពុជា

(១៨). ដើម្បីសម្រេចនូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ យុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាល គឺការរៀបចំនិងការដាក់ចេញនូវវិធានការគោលនយោបាយសំដៅរួមចំណែកបង្កើតឡើងនូវបរិស្ថានអំណោយផល

សម្រាប់បន្តលើកកម្ពស់ការចូលរួមរបស់វិស័យឯកជន សហគមន៍មូលដ្ឋាន គ្រឹះស្ថានហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍ ក្នុងការអភិវឌ្ឍអេកូទេសចរណ៍នៅកម្ពុជា តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ប្រជាពលរដ្ឋមូលដ្ឋាននិងដៃគូអភិវឌ្ឍ(4P) ដោយនឹងអនុវត្តតាមអភិក្រម ប្រយ័ត្នប្រយែងជាជំហានៗដែលរួមមាន៖

(១). ការចាប់ផ្តើមពីការពិនិត្យនិងកែសម្រួលនូវក្របខណ្ឌគតិយុត្ត ការរៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការ ការបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុតាមការចាំបាច់ និងការកំណត់យន្តការស្ថាប័នឱ្យបានច្បាស់លាស់ ព្រមទាំងការបង្កើតក្រុមការងារអន្តរក្រសួង ជាស្ថាប័នសម្រាប់គ្រប់គ្រងនិងសម្របសម្រួលអនុវត្តយុទ្ធសាស្ត្រនេះ។

(២). អភិក្រម **"រៀនផងធ្វើផង"** ដោយរៀនសូត្រពីបទពិសោធជាក់ស្តែងទៅគ្រប់ដំណាក់កាលអនុវត្តនៃវដ្តរបស់គម្រោងអភិវឌ្ឍអេកូទេសចរណ៍ ជាពិសេស ការធ្វើអត្តសញ្ញាណកម្មគម្រោង រៀបចំបញ្ជីគម្រោងអាទិភាព សិក្សាសមិទ្ធិលទ្ធភាព និងគ្រប់គ្រងការអនុវត្តគម្រោង ដើម្បីឈានទៅធ្វើការកែលំអប្រព័ន្ធគ្រប់គ្រងយន្តការ(4P) ក្នុងការអភិវឌ្ឍអេកូទេសចរណ៍នៅកម្ពុជាឱ្យមានសុក្រឹតភាព ប្រសិទ្ធភាព និងសក្តិសិទ្ធភាព។ ក្នុងដំណាក់កាល **"រៀនផងធ្វើផង"** នេះ ដោយឈរលើគោលការណ៍ប្រុងប្រយ័ត្នខ្ពស់ រាជរដ្ឋាភិបាលនឹងដាក់ឱ្យអនុវត្តតែ៖

- គម្រោងដែលផ្តួចផ្តើមដោយរដ្ឋឬសហគមន៍ ឬដោយដៃគូអភិវឌ្ឍសម្រាប់គម្រោងអភិវឌ្ឍអេកូទេសចរណ៍ (ខ្នាតតូច) ដែលទីតាំងនេះមានវត្តមានប្រជាពលរដ្ឋមូលដ្ឋានស្រាប់។
- រាជរដ្ឋាភិបាលនៅតែរក្សាភាពទន់ភ្លន់និងហ្មត់ចត់ក្នុងការទទួលយកគម្រោងដឹកនាំដោយផ្នែកឯកជនមួយចំនួន ដែលមាននវានុវត្តភាពកម្រិតខ្ពស់មកពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តផងដែរ។

(៣). ការអភិវឌ្ឍសមត្ថភាពស្ថាប័ននិងធនធានមនុស្សកម្រិតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋាន។

(១៩). ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍអេកូទេសចរណ៍នៅកម្ពុជា មានដូចខាងក្រោម៖

### ៤.១. ធ្វើផែនការនិងបែងចែកជាតំបន់អេកូទេសចរណ៍អាទិភាព និងរៀបចំរមណីយដ្ឋានអេកូទេសចរណ៍គំរូ

(២០). យុទ្ធសាស្ត្រក្នុងការធ្វើផែនការនិងបែងចែកជាតំបន់អាទិភាព និងការរៀបចំរមណីយដ្ឋានអេកូទេសចរណ៍រួមមាន៖

- កំណត់ជាតំបន់អេកូទេសចរណ៍អាទិភាពចំនួន៤ រួមមាន៖ តំបន់ភូមិភាគឦសាន តំបន់បឹងទន្លេសាប និងទន្លេមេគង្គ តំបន់ឆ្នេរសមុទ្រ និងតំបន់ជួរភ្នំក្រវាញ ព្រមទាំងធ្វើការកំណត់អត្តសញ្ញាណកម្ម (Mapping) រមណីយដ្ឋានអេកូទេសចរណ៍នៅតាមតំបន់អាទិភាពនីមួយៗ។
- រៀបចំអភិវឌ្ឍជារមណីយដ្ឋានអេកូទេសចរណ៍គំរូយ៉ាងហោចមួយនៅតាមតំបន់អាទិភាពនីមួយៗ ដែលអាចបម្រើឱ្យភ្ញៀវទេសចរស្នាក់នៅរយៈពេលខ្លី មធ្យម និងវែង (ទេសចរផ្ទះទីពីរ)។
- តម្រូវឱ្យមានផែនការមេអភិវឌ្ឍអេកូទេសចរណ៍សម្រាប់គម្រោងអភិវឌ្ឍអេកូទេសចរណ៍នីមួយៗ ដោយត្រូវគិតគូរអំពីការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុផង និងឆ្លើយតបតម្រូវការចាំបាច់នៃការអភិវឌ្ឍឱ្យបានជាអតិបរមាផង ស្របតាមគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍអេកូទេសចរណ៍។
- រាល់គម្រោងអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ត្រូវមាន៖
  - ត្រូវមានការកំណត់តួនាទីច្បាស់លាស់នៃគ្រប់ភាគីពាក់ព័ន្ធ។

- ត្រូវមានគម្រោងអាជីវកម្មសម្រាប់រាល់គម្រោងអភិវឌ្ឍអេកូទេសចរណ៍ យន្តការបែងចែកប្រាក់ចំណេញ ការសិក្សាទីផ្សារនិងផ្សព្វផ្សាយ គំរូហិរញ្ញប្បទាន ផែនការគ្រប់គ្រងហានិភ័យជាដើម
- ត្រូវមានការពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានទាក់ទងនឹងការគ្រប់គ្រងសំណល់រឹងនិងរាវច្បាស់លាស់។
- ត្រូវមានយន្តការគ្រប់គ្រងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ក្នុងរមណីយដ្ឋានអេកូទេសចណ៍។
- ត្រូវមានការវិភាគសមត្ថភាពផ្ទុកនៅតាមរមណីយដ្ឋានអេកូទេសចរណ៍នីមួយៗ ដើម្បីកំណត់បរិមាណអតិបរមានៃភ្ញៀវទេសចរចូលទស្សនាតាមរមណីយដ្ឋាននីមួយៗ។

- រៀបចំឱ្យមានមូលនិធិទ្រទ្រង់ដល់ការសិក្សារៀបចំគម្រោងក្នុងដំណាក់កាលសមិទ្ធិលទ្ធភាព។
- តម្រូវឱ្យអ្នកអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ គឺជាសហគមន៍មូលដ្ឋានសម្រាប់រាល់គម្រោងស្ថិតលើទីតាំងដែលមានប្រជាសហគមន៍មូលដ្ឋានស្រាប់។
- រៀបចំបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងលើការតុបតែងរចនា ការស្ថាបនា និងប្រតិបត្តិការ (DBO) នៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សម្បទា និងសេវាកម្មទេសចរណ៍ចាំបាច់នានាក្នុងរមណីយដ្ឋានអេកូទេសចរណ៍។

### ៤.២. ការបង្កើនលទ្ធភាពធ្វើអាជីវកម្មនិងវិនិយោគទេសចរណ៍ក្នុងរមណីយដ្ឋានអេកូទេសចរណ៍

(២១). យុទ្ធសាស្ត្រក្នុងការបង្កើនលទ្ធភាពធ្វើអាជីវកម្មនិងវិនិយោគទេសចរណ៍ រួមមានៈ

- ធានាឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាពនិងការទទួលខុសត្រូវខ្ពស់ក្នុងតំបន់ការពារធម្មជាតិដោយផ្តល់ឱ្យគម្រោងអភិវឌ្ឍអេកូទេសចរណ៍មានលក្ខណសម្បត្តិជាតំបន់ទេសចរណ៍ពិសេស
- ធានាឱ្យបាននូវគោលការណ៍និរន្តរភាព ត្រូវរៀបចំគោលការណ៍ណែនាំច្បាស់លាស់សម្រាប់រាល់ទម្រង់នៃជម្រើសជាយុទ្ធសាស្ត្រចំពោះការអនុវត្ត គម្រោងអភិវឌ្ឍអេកូទេសចរណ៍ខ្នាតតូចនិងខ្នាតធំ ព្រមទាំងកំណត់លក្ខណវិនិច្ឆ័យសម្រាប់រៀបចំប្លង់មេអភិវឌ្ឍគ្រប់គម្រោងអេកូទេសចរណ៍
- បង្កើតនូវប្រភេទមូលនិធិបរធនបាលកិច្ច (Trust Fund) សម្រាប់គាំទ្រគម្រោងអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ (ខ្នាតតូចនិងខ្នាតធំ)
- លើកទឹកចិត្តផ្នែកវិនិយោគឯកជនក្នុងការអភិវឌ្ឍនិងរៀបចំរមណីយដ្ឋានអេកូទេសចរណ៍ (ខ្នាតធំ) នៅតំបន់ការពារធម្មជាតិ តាមរយៈការលើកទឹកចិត្តផ្នែកវិនិយោគផ្តល់លក្ខណសម្បត្តិជាតំបន់ទេសចរណ៍ពិសេស ដល់អ្នកអភិវឌ្ឍ និងរៀបចំរមណីយដ្ឋានអេកូទេសចរណ៍ និងគាំទ្រការអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍(ខ្នាតធំ) តាមរយៈការផ្តល់ការគាំទ្រ ដោយប្រើប្រាស់យន្តការភាពជាដៃគូរដ្ឋ-ឯកជនប្រជាពលរដ្ឋ (PPP)
- គាំទ្រការអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍(ខ្នាតតូច) តាមរយៈការផ្តល់ការគាំទ្រដោយប្រើប្រាស់យន្តការភាពជាដៃគូរដ្ឋ-ឯកជន-សហគមន៍-ដៃគូអភិវឌ្ឍ និងផ្តល់លក្ខណសម្បត្តិជាតំបន់ទេសចរណ៍ពិសេស
- រៀបចំប្រព័ន្ធហិរញ្ញប្បទានអនុគ្រោះ ដើម្បីផ្តល់មូលនិធិដល់ប្រតិបត្តិករទេសចរណ៍ ដែលមានអាជីវកម្មក្នុងរមណីយដ្ឋានអេកូទេសចរណ៍
- ពង្រឹងសមត្ថភាពហិរញ្ញវត្ថុនិងបច្ចេកទេសក្នុងការធ្វើអាជីវកម្មនិងវិនិយោគក្នុងរមណីយដ្ឋានអេកូទេស-ចរណ៍ តាមរយៈការបង្កើតក្លឹបអ្នកវិនិយោគក្នុងវិស័យទេសចរណ៍ និងបណ្តាញសហគមន៍ទេសចរណ៍/អេកូទេសចរណ៍កម្ពុជា។

- គាំទ្រសមត្ថភាពហិរញ្ញវត្ថុនិងបច្ចេកទេសដល់ប្រតិបត្តិករទេសចរណ៍ជាសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម ដែលធ្វើអាជីវកម្មក្នុងរមណីយដ្ឋានអេកូទេសចរណ៍ សំដៅពង្រឹងគុណភាពនិងពង្រីកសេវាកម្មទេសចរណ៍ក្នុងរមណីយដ្ឋានទេសចរណ៍
- រៀបចំគម្រោងកម្មវិធីពិសេសរបស់រាជរដ្ឋាភិបាលគាំទ្រលើការវិនិយោគនិងរៀបចំរមណីយដ្ឋានអេកូទេសចរណ៍ (ខ្នាតតូច) មានក្នុងតំបន់ការពារធម្មជាតិឬឧទ្យានជាតិ ដែលត្រូវបានកំណត់ជាអាទិភាព។

## ៤.៣- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ(រូបវន្តនិងទន់) និងការវិភាគសមត្ថភាពផ្ទុកក្នុងរមណីយដ្ឋានអេកូទេសចរណ៍

### ៤.៣.១- យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទន់៖

- ពង្រឹងសមត្ថភាពដល់អ្នកសម្រេចចិត្តនិងអ្នកអនុវត្តគោលនយោបាយអេកូទេសចរណ៍
- ផ្តល់ការបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពដល់អ្នកអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ និងផ្តល់ការទទួលស្គាល់ជាប្រតិបត្តិករដែលមានប្រវត្តិនិងស្នាដៃខាងបរិស្ថាននិងសង្គម(ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍)
- ពិនិត្យ សិក្សា ធ្វើបច្ចុប្បន្នកម្ម និងកសាងបទដ្ឋានគតិយុត្តចាំបាច់នានាដែលទាក់ទងនឹងសកម្មភាពអេកូទេសចរណ៍
- បណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍នៅក្នុងរមណីយដ្ឋានអេកូទេសចរណ៍
- រៀបចំក្រុមបណ្តុះបណ្តាលជំនាញចល័តដើម្បីធ្វើការសម្របសម្រួលនិងអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលឱ្យមានលក្ខណៈស្តង់ដា និងរៀបចំឯកសារសិក្សាសម្រាប់សហគមន៍ និងប្រជាពលរដ្ឋមូលដ្ឋាន។

### ៤.៣.២- យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត:

- ត្រូវកសាងផ្លូវចូលឆ្ពោះទៅកាន់រមណីយដ្ឋានអេកូទេសចរណ៍ឱ្យបានគ្រប់គ្រាន់
- ជំរុញនិងលើកទឹកចិត្តឲ្យកសាងហេដ្ឋារចនាសម្ព័ន្ធដែលអាចមានឥទ្ធិពលអវិជ្ជមានតិចតួចដល់បរិស្ថាន វប្បធម៌ ដោយត្រូវគិតគូរលើរចនាបទអាគារ គំរូស្ថាបត្យកម្មជាក់លាក់ និងគោរពវប្បធម៌នៅតាមមូលដ្ឋាន(ដូចជាអេកូឡូច) ដោយទប់ស្កាត់ការសាងសង់សំណង់ធំៗក្នុងតំបន់អភិរក្ស និងតំបន់ការពារនានា
- ត្រូវកសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដូចជាស្លាកសញ្ញាសំគាល់សម្រាប់ភ្ញៀវ ផ្លូវដើរទស្សនាធុងសំរាមដែលមានការបែងចែកត្រឹមត្រូវ មជ្ឈមណ្ឌលព័ត៌មានទេសចរណ៍ សារមន្ទីរ ផែនទី ស្លាកសញ្ញាផ្តល់ព័ត៌មានបង្ហាញពីផ្លូវធ្វើដំណើរក្នុងព្រៃ បង្គន់ និងកន្លែងទស្សនានៅរមណីយដ្ឋានអេកូទេសចរណ៍
- ជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញ ក្នុងគោលបំណងបម្រើឱ្យសកម្មភាពទេសចរណ៍នៅរមណីយដ្ឋានអេកូទេសចរណ៍
- ជំរុញការប្រើប្រាស់សេវាដឹកជញ្ជូនដែលគោរពតាមស្តង់ដាបរិស្ថានក្នុងរមណីយដ្ឋានអេកូទេសចរណ៍។

## ៤.៤. ការអភិវឌ្ឍនិងពង្រឹងគុណភាពសេវាកម្មទេសចរណ៍ក្នុងរមណីយដ្ឋានអេកូទេសចរណ៍

- ធ្វើអធិការកិច្ចផ្នែកបរិស្ថានឱ្យបានទៀងទាត់លើរាល់ការអនុវត្តរបស់ប្រតិបត្តិករទេសចរណ៍នានា ក្នុងរមណីយដ្ឋានអេកូទេសចរណ៍
- ពង្រឹងគុណភាពនៃការអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ខ្នាតតូច ឱ្យស្របតាមស្តង់ដាសហគមន៍ទេសចរណ៍កម្ពុជា

- បង្កើតឱ្យមានស្តង់ដា សូចនាករ និង/ឬគោលការណ៍ណែនាំផ្នែកបរិស្ថាន និងសង្គមឱ្យបានលំអិតសម្រាប់ប្រតិបត្តិការ និងអាជីវកម្មក្នុងតំបន់អេកូទេសចរណ៍
- កសាងនិងពង្រឹងសមត្ថភាពមគ្គុទ្ទេសក៍ទេសចរណ៍ ក្នុងរមណីយដ្ឋានអេកូទេសចរណ៍ (មគ្គុទ្ទេសក៍ទេសចរណ៍សហគមន៍) ដើម្បីធានាដល់ការផ្តល់ព័ត៌មានច្បាស់លាស់ប្រកបដោយគុណភាពដល់ភ្ញៀវទេសចរ
- ប្រតិបត្តិករទេសចរណ៍ ដែលធ្វើអាជីវកម្មក្នុងរមណីយដ្ឋានអេកូទេសចរណ៍ត្រូវគោរពតាមស្តង់ដា និងគោលការណ៍ណែនាំនានា ផ្នែកបរិស្ថាននិងសង្គម និងត្រូវធ្លាប់ទទួលបាន**ជ័យលាភីរង្វាន់សម្តេចតេជោនាយករដ្ឋមន្ត្រីសម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍**
- អភិវឌ្ឍនិងជំរុញការលក់វត្ថុអនុស្សាវរីយ៍ដែលផលិតនៅក្នុងសហគមន៍(មានការគិតគូរលើវប្បធម៌ ប្រពៃណី និងធានាថាមានឥទ្ធិពលអប្បបរមាលើធនធានធម្មជាតិ) ដល់ភ្ញៀវទេសចរ និងផ្គត់ផ្គង់ផលិតផលសរីរាង្គដល់ភ្ញៀវទេសចរ
- ពង្រឹងនិងពង្រីកសកម្មភាពអេកូទេសចរណ៍ ដូចជាការទស្សនាសត្វស្លាប ថនិកសត្វ សត្វចតុប្បាទ ការថតទេសភាព ខ្សែទស្សនកិច្ចស្វែងយល់ប្រពៃណី និងធម្មជាតិ របាំ ការជិះកង់ ដំណើររុករកក្នុងព្រៃ ឡើងភ្នំ ជាដើម
- រៀបចំមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍នៅតាមរមណីយដ្ឋានអេកូទេសចរណ៍នីមួយៗ
- រៀបចំពិធីបុណ្យដែលផ្សារភ្ជាប់នឹងការអភិរក្សធនធានធម្មជាតិនិងជីវៈចម្រុះ ដូចជាពិធីបុណ្យសមុទ្រ បុណ្យទន្លេ បុណ្យទស្សនាសត្វស្លាប បុណ្យបំបួសដើមឈើជាដើម
- ពង្រឹងគុណភាពសេវាកម្មផ្ទះស្នាក់នៅតាមសហគមន៍ ឱ្យស្របតាមស្តង់ដាផ្ទះស្នាក់កម្ពុជា ពិសេស ឆ្លើយតបនឹងតម្រូវការរបស់ភ្ញៀវទេសចរ (ដូចជាបន្ទប់ទឹក បង្គន់ បន្ទប់ស្នាក់ និងសេវាផ្សេងៗ)
- ធានាឱ្យមានតម្លាភាពក្នុងការកំណត់តម្លៃសេវាកម្មក្នុងរមណីយដ្ឋានអេកូទេសចរណ៍
- រៀបចំឱ្យមាន**វិញ្ញាបនបត្របៃតង** (Eco-Certification) សម្រាប់អាជីវកម្មនៅតាមរមណីយដ្ឋានអេកូទេសចរណ៍
- បង្កើតកម្មវិធី "**ពានរង្វាន់អេកូទេសចរណ៍កម្ពុជា**" ប្រចាំឆ្នាំដើម្បីទទួលស្គាល់និងលើកទឹកចិត្តដល់អ្នកអនុវត្តល្អៗ (ប្រតិបត្តិករទេសចរណ៍ សហគមន៍ អ្នកផ្គត់ផ្គង់សេវា។ល។) ក្នុងការអភិវឌ្ឍអេកូទេសចរណ៍នៅតាមគោលដៅនីមួយៗ។

### ៤.៥- ការសិក្សាទីផ្សារនិងផ្សព្វផ្សាយអេកូទេសចរណ៍

**(២២).** យុទ្ធសាស្ត្រក្នុងការសិក្សាទីផ្សារនិងផ្សព្វផ្សាយអេកូទេសចរណ៍ រួមមាន៖

- ជំរុញការផ្សព្វផ្សាយអេកូទេសចរណ៍ទៅកាន់ទីផ្សារអន្តរជាតិ
- រៀបចំយុទ្ធសាស្ត្រសិក្សាទីផ្សារនិងផ្សព្វផ្សាយសម្រាប់ទីផ្សារអេកូទេសចរណ៍កម្ពុជា
- បង្កើតវេទិការួមដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន សហគមន៍ទេសចរណ៍ អង្គការជាតិនិងអន្តរជាតិ សម្រាប់ការងារសិក្សាទីផ្សារក្នុងផ្នែកអេកូទេសចរណ៍
- បង្កើតទិន្នន័យថ្នាក់ជាតិ ដោយសិក្សាស្រាវជ្រាវ ធ្វើបច្ចុប្បន្នកម្មលើតម្រូវការ និងនិន្នាការនៃទីផ្សារអេកូទេសចរណ៍នៅកម្រិតសកលលោក តំបន់ និងថ្នាក់ជាតិ និងរៀបចំអង្កេត និងធ្វើបច្ចុប្បន្នកម្មទីផ្សារអេកូទេសចរណ៍ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំយុទ្ធសាស្ត្រសិក្សាទីផ្សារ និងផ្សព្វផ្សាយអេកូទេសចរណ៍

- ធ្វើការផ្សព្វផ្សាយ Branding កម្ពុជាជាគោលដៅអេកូទេសចរណ៍ដ៏ទាក់ទាញ ក្រោមពាក្យស្លោក "**ការស្វែងរកពិភពបៃតង**" ដែលជាផ្នែកមួយនៃ "**កម្ពុជា ៖ ព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅ**"
- ជំរុញការផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យាទំនើបដោយរៀបចំជា គេហទំព័រផ្សព្វផ្សាយ កម្មវិធីទូរស័ព្ទចល័ត (Mobile App) អំពីអេកូទេសចរណ៍កម្ពុជា
- ផ្សព្វផ្សាយនិងទាក់ទាញទេសចរកម្រិតខ្ពស់ ទេសចរយុវជន ទេសចរផ្ទះទីពីរ មកកាន់រមណីយដ្ឋានអេកូទេសចរណ៍។

**៤.៦- ការធានាសុវត្ថិភាពនៅតាមរមណីយដ្ឋានអេកូទេសចរណ៍**

(២៣). យុទ្ធសាស្ត្រធានាសុវត្ថិភាពនៅរមណីយដ្ឋានអេកូទេសចរណ៍រួមមាន៖

- បណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍នូវចំណេះដឹងសង្គ្រោះបឋម ដើម្បីមានលទ្ធភាពសង្គ្រោះភ្ញៀវនៅពេលមានគ្រោះថ្នាក់
- រៀបចំប្រព័ន្ធសន្តិសុខសុវត្ថិភាពទេសចរណ៍ និងប្រព័ន្ធសង្គ្រោះបន្ទាន់នៅតាមរមណីយដ្ឋានអេកូទេសចរណ៍នីមួយៗ ព្រមទាំងបើកវគ្គបណ្តុះបណ្តាលអំពីប្រព័ន្ធទាំងនេះដល់សហគមន៍ ប្រតិបត្តិករទេសចរណ៍ និងគ្រប់ភាគីពាក់ព័ន្ធដែលធ្វើអាជីវកម្មក្នុងរមណីយដ្ឋានអេកូទេសចរណ៍
- រៀបចំផែនទីចង្អុលចំណុច/តំបន់គ្រោះថ្នាក់នៅតាមរមណីយដ្ឋានអេកូទេសចរណ៍នីមួយៗ។

**៤.៧. ការបញ្ជ្រាបការយល់ដឹងនិងអប់រំអំពីអេកូទេសចរណ៍**

- ជំរុញរៀបចំវគ្គសិក្សាកម្រិតឧត្តមសិក្សានិងថ្នាក់ជំនាញវិជ្ជាជីវៈផ្នែកអេកូទេសចរណ៍នៅតាមគ្រឹះស្ថានឧត្តមសិក្សា និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍
- រៀបចំកម្មវិធីផ្សព្វផ្សាយការយល់ដឹងជាសាធារណៈពីអេកូទេសចរណ៍ដល់គ្រប់ភាគីពាក់ព័ន្ធ
- លើកកម្ពស់ការយល់ដឹងអំពីទស្សនាទាននៃអេកូទេសចរណ៍ ផលប៉ះពាល់ ផលប្រយោជន៍ កាលានុវត្តភាព និងផលវិបាកនៃការអភិវឌ្ឍអេកូទេសចរណ៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិមូលដ្ឋាន សិស្ស និស្សិត ប្រជាពលរដ្ឋមូលដ្ឋាន ភ្ញៀវទេសចរ និងគ្រប់ភាគីពាក់ព័ន្ធ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ កម្មវិធីសិក្សាជាដើម
- បង្កើនការយល់ដឹងដល់ភ្ញៀវទេសចរអំពី**គោលការណ៍របស់អេកូទេសចរណ៍** បទពិសោធល្អៗ និងការប្រតិបត្តិអំពី **"អ្វីដែលគួរធ្វើ"** និង **"អ្វីដែលមិនគួរធ្វើ"** នៅក្នុងរមណីយដ្ឋានអេកូទេសចរណ៍
- ផ្តល់ការបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពដល់ប្រតិបត្តិករទេសចរណ៍ សហគមន៍ទេសចរណ៍ អាជីវករអេកូទេសចរណ៍ និងភាគីពាក់ព័ន្ធឱ្យយល់ដឹងពីផ្នែកអេកូទេសចរណ៍
- ជំរុញឱ្យមានការរៀបចំទស្សនកិច្ចសិក្សាស្វែងយល់ពីធម្មជាតិនៅតាមតំបន់ធម្មជាតិ តំបន់អេកូទេសចរណ៍ដល់កម្មករ បុគ្គលិក សិស្ស និស្សិត និងមន្ត្រីរាជការ
- រៀបចំការបណ្តុះបណ្តាលសម្រាប់សហគមន៍មូលដ្ឋានអំពីចំណេះដឹងលើវិស័យទេសចរណ៍(ពិសេសផ្តោតលើតួនាទីរបស់សហគមន៍ទេសចរណ៍/អេកូទេសចរណ៍) និងការអភិរក្ស របៀបធ្វើអាជីវកម្មបម្រើឱ្យភ្ញៀវទេសចរនៅថ្នាក់មូលដ្ឋាន ការគ្រប់គ្រងហិរញ្ញកិច្ច ការងារបដិសណ្ឋារកិច្ច មគ្គុទ្ទេសក៍ ការគ្រប់គ្រងសំណល់រឹងនិងរាវ។ល។
- រៀបចំការបណ្តុះបណ្តាលសម្រាប់ផ្នែកឯកជន អំពីតួនាទីនៃវិស័យទេសចរណ៍ដែលមានលក្ខណៈជាប្រព័ន្ធ តួនាទីរបស់ផ្នែកឯកជននៅក្នុងការអភិវឌ្ឍវិស័យទេសចរណ៍ ជំនាញអាជីវកម្ម ការស្វែងរកហិរញ្ញប្បទាន

ការសិក្សាទីផ្សារ ការផ្គត់ផ្គង់ *"ផលិតផលខ្មែរបម្រើឱ្យភ្ញៀវទេសចរ"* និងការស្វែងយល់អំពីតម្រូវការភ្ញៀវទេសចរ។ល។

- ជំរុញចលនាផ្សព្វផ្សាយការយល់ដឹងពីសក្តានុពលធម្មជាតិនិងអេកូទេសចរណ៍ដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ការរៀបចំជាចំរៀងទេសចរណ៍ ស្ពតអប់រំ។ល។
- បង្កើតកម្មវិធីអប់រំអេកូទេសចរណ៍ដែលមានលក្ខណៈទន់ភ្លន់ សម្រាប់ភ្ញៀវទេសចរឱ្យយល់ដឹងអំពីព័ត៌មានចាំបាច់មួយចំនួន ដូចជាប្រព័ន្ធអេកូឡូស៊ី ប្រវត្តិ និងវប្បធម៌របស់ប្រជាជនមូលដ្ឋាន តួនាទីរបស់ភ្ញៀវទេសចរក្នុងការចូលរួមដល់កិច្ចគាំពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិរបស់គោលដៅអេកូ-ទេសចរណ៍ផ្សារភ្ជាប់នឹងមជ្ឈមណ្ឌលព័ត៌មានទេសចរណ៍
- រៀបចំកម្មវិធីអប់រំបណ្តុះបណ្តាលនិងផែនការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដល់សហគមន៍ប្រជាពលរដ្ឋមូលដ្ឋាន សិស្សានុសិស្សចាប់ពីកម្រិតបឋមសិក្សាពីកិច្ចគាំពារបរិស្ថាននិងអភិរក្សធនធានធម្មជាតិ តាមរយៈការអភិវឌ្ឍអេកូទេសចរណ៍។

**៥- ផែនការសកម្មភាព**

**៥.១- ការបង្កើតនិងការពង្រឹងយន្តការស្ថាប័ន**

(២៤). យន្តការស្ថាប័នសម្រាប់ពង្រឹងការសម្របសម្រួល ការត្រួតពិនិត្យ និងការអនុវត្តគោលនយោបាយជាតិអេកូទេសចរណ៍មាន **៣កម្រិត** រួមមានៈ

**ទី១- ការពង្រឹងយន្តការសម្របសម្រួលថ្នាក់ជាតិ**

- បង្កើត**ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍** ដោយមានសមាសភាពចូលរួមពី**ក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ** ព្រមទាំងមានការចូលរួមពីតំណាងផ្នែកឯកជន តំណាងសង្គមស៊ីវិល និងតំណាងសហគមន៍ផងដែរដោយផ្តោតទៅលើៈ
  - ធ្វើបច្ចុប្បន្នកម្ម ត្រួតពិនិត្យ និងវាយតម្លៃឱ្យបានទៀងទាត់នូវប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិអេកូទេសចរណ៍
  - ពិនិត្យនិងផ្តល់យោបល់ដល់ក្រសួងស្ថាប័នពាក់ព័ន្ធ អនុវត្តគម្រោងនានាបម្រើឱ្យការអភិវឌ្ឍគម្រោងអេកូទេសចរណ៍
  - រៀបចំនិងធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រជាតិអភិវឌ្ឍអេកូទេសចរណ៍
  - រៀបចំផែនការសកម្មភាពអភិវឌ្ឍអេកូទេសចរណ៍រយៈពេលខ្លី មធ្យម និងវែង
  - បញ្ជ្រាបការយល់ដឹងនិងផ្សព្វផ្សាយអំពីអេកូទេសចរណ៍កម្ពុជា
  - វាយតម្លៃនិងទទួលស្គាល់សហគមន៍អេកូទេសចរណ៍/ទេសចរណ៍
  - ពិនិត្យ វាយតម្លៃ និងសម្រេចលើគម្រោងអេកូទេសចរណ៍អនុវត្តដោយសហគមន៍ឬអង្គការជាតិនិងអន្តរជាតិ
  - ពិនិត្យនិងវាយតម្លៃលើសមិទ្ធិលទ្ធភាពគម្រោងអភិវឌ្ឍអេកូទេសចរណ៍
  - ពិនិត្យនិងតាមដានរាល់ប្រតិបត្តិការរបស់គម្រោងអភិវឌ្ឍអេកូទេសចរណ៍

▪ រៀបចំបទដ្ឋានគតិយុត្តចាំបាច់នានា ដើម្បីគ្រប់គ្រងអេកូទេសចរណ៍ ប្រកបដោយនិរន្តរភាពនិងការទទួលខុសត្រូវ

▪ ដោះស្រាយជាបន្ទាន់នូវរាល់កិច្ចការទាំងឡាយដែលកើតមាននៅក្នុងរមណីយដ្ឋានអេកូទេសចរណ៍ទាំងលើទិដ្ឋភាពបច្ចេកទេស ទិដ្ឋភាពច្បាប់ ឬដែលស្ថិតក្នុងសមត្ថកិច្ចចម្រុះត្រូវដោះស្រាយដោយអន្តរក្រសួង

▪ ស្វែងរកប្រភពហិរញ្ញប្បទានជួយអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍

▪ គ្រប់គ្រងនិងចាត់ចែងមូលនិធិអេកូទេសចរណ៍

▪ ទទួលពាក្យតវ៉ានិងដោះស្រាយវិវាទរវាង**អ្នកអភិវឌ្ឍតំបន់និងប្រតិបត្តិករអេកូទេសចរណ៍** ក្នុងរមណីយដ្ឋានអេកូទេសចរណ៍

▪ ផ្តល់ជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុចាំបាច់ដល់សហគមន៍ និងប្រតិបត្តិករអេកូទេសចរណ៍ករណីចាំបាច់។

**ទី២- ការពង្រឹងយន្តការសម្របសម្រួលថ្នាក់ក្រោមជាតិ**

- គណៈកម្មការអភិវឌ្ឍទេសចរណ៍រាជធានីខេត្ត មានភារកិច្ចគ្រប់គ្រង និងអនុម័តរាល់សំណើស្នើសុំអនុញ្ញាតអាជីវកម្មនានារបស់ប្រតិបត្តិករអេកូទេសចរណ៍ក្នុងរមណីយដ្ឋានអេកូទេសចរណ៍ ការបណ្តុះបណ្តាលធនធានមនុស្ស ការពង្រឹងសមត្ថភាពសហគមន៍ និងក៏ត្រូវមានការគិតគូរដល់ការបញ្ចូលផែនការអភិវឌ្ឍអេកូទេសចរណ៍ ទៅក្នុងផែនការអភិវឌ្ឍអេកូទេសចរណ៍ថ្នាក់តំបន់និងផែនការថ្នាក់ជាតិ ដោយធ្វើបច្ចុប្បន្នកម្ម ឬរៀបចំផែនការអភិវឌ្ឍអេកូទេសចរណ៍សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដែលស្ថិតនៅក្នុងតំបន់អាទិភាពអេកូទេសចរណ៍ទាំង៤ ដូចខាងក្រោម៖

*ផែនទីតំបន់អាទិភាពអេកូទេសចរណ៍*



**១- តំបន់ភូមិភាគឦសាន**

**(២៥)**. ជាតំបន់សក្តានុពលអភិវឌ្ឍទេសចរណ៍ធម្មជាតិនិងអេកូទេសចរណ៍ធំ ដែលរួមមានឧទ្យានជាតិវីរជ័យ ដងទន្លេមេគង្គ ជីវៈចម្រុះ តំបន់ខ្ពង់រាប សហគមន៍ជនជាតិភាគតិច សត្វដំរី និងពពួកសត្វព្រៃកម្រផ្សេងៗទៀត ពិសេស សត្វផ្សោតទឹកសាប(ក្នុងខេត្តក្រចេះនិងស្ទឹងត្រែង ដែលជាផលិតផលទេសចរណ៍ទោលក្នុងតំបន់អាស៊ី) និងសត្វក្រៀល ត្រីខ្យានៅតាមដងទន្លេមេគង្គ។ល។

**២- តំបន់បឹងទន្លេសាបនិងទន្លេមេគង្គ**

**(២៦)**. តំបន់បឹងទន្លេសាបនិងទន្លេមេគង្គដែលមានទឹកហូរបញ្ច្រាសទិសគ្នាបានផ្តល់នូវធនធានធម្មជាតិដ៏វិសេសវិសាល បម្រើឱ្យការអភិវឌ្ឍវិស័យទេសចរណ៍ ពិសេស ផ្នែកអេកូទេសចរណ៍។ ទន្លេសាបជាតំបន់ដែនជីវៈចម្រុះដ៏ធំនៅក្នុងតំបន់អាស៊ីត្រូវបានបង្កើតឡើងនៅឆ្នាំ២០០១ ដែលបានចែកជា**៣តំបន់ការពារៈ តំបន់ព្រែកទាល់ បឹងទន្លេឆ្មា និងស្ទឹងសែន**។ ជាកាពិត ព្រែកទាល់គឺជាតំបន់ស្នូលមួយក្នុងចំណោមតំបន់ស្នូលនានានៃដែនជីវៈចម្រុះទន្លេសាប ដែលត្រូវបានទទួលស្គាល់ថាជាជម្រកធំទីមួយសម្រាប់បក្សីទឹកធំៗ ហើយក៏មានផ្ទះបណ្តែតទឹកដែលបានបង្ហាញពីប្រពៃណី និងរបៀបរបបរស់នៅរបស់ប្រជាជននៅជុំវិញតំបន់នេះ។

**៣- តំបន់ឆ្នេរសមុទ្រ**

**(២៧)**. ដោយឈរលើសក្តានុពលធនធានធម្មជាតិដ៏វិសេសវិសាលនិងភាពសម្បូរបែបនៃបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ ជាអាទិ៍ ព្រៃកោងកាងធំជាងគេនៅអាស៊ីអាគ្នេយ៍ ឆ្នេរខ្សាច់ពណ៌ស ទឹកសមុទ្រពណ៌ខៀវស្រងាត់ កោះ ធនធានក្រោមសមុទ្រ និងជីវៈចម្រុះដ៏សំបូរបែប **ឆ្នេរសមុទ្រកម្ពុជា**ដែលលាតសន្ធឹងលើប្រវែង ៤៤០គីឡូម៉ែត្រ បានក្លាយជាសមាជិក**ក្លឹបឆ្នេរសមុទ្រដែលស្អាតជាងគេបំផុតលើសកលលោក**។

**៤- តំបន់ជួរភ្នំក្រវាញ**

**(២៨)**. តំបន់ជួរភ្នំក្រវាញជាតំបន់អេកូឡូស៊ីដ៏ធំមួយនៅលើពិភពលោក។ ភ្នំក្រវាញលាតសន្ធឹងលើផ្ទៃក្រឡាជាង **១លានហិចតា** ដោយមានភ្នំសំខាន់ៗនៅជុំវិញ(រួមទាំងតំបន់អារ៉ែង) មានវិសាលភាពធំធេង សម្បូរទៅដោយពពួកសត្វកម្រនិងជីវៈចម្រុះសម្បូរបែប ហើយតំបន់នេះត្រូវបានបញ្ចូលទៅក្នុងតំបន់អេកូទេសចរណ៍ល្បីៗ ទាំង១០ នៅលើពិភពលោក។

**ទី៣- ការពង្រឹងយន្តការគ្រប់គ្រងថ្នាក់រមណីយដ្ឋាន/សហគមន៍៖**

- ក្នុងការគ្រប់គ្រងនិងអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ ត្រូវរៀបចំបង្កើតឡើងនូវ**អ្នកអភិវឌ្ឍរមណីយដ្ឋាន** (Resort Developer) ដែលជាអ្នកអនុវត្តគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដែលទទួលបានការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីអភិវឌ្ឍសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ចាត់តាំងការធ្វើអាជីវកម្មសេវាកម្មទេសចរណ៍របស់ប្រតិបត្តិករទេសចរណ៍ ដែលជាអ្នកវិនិយោគក្នុងរមណីយដ្ឋានអេកូទេសចរណ៍ឱ្យមានគុណភាពបម្រើដល់ភ្ញៀវទេសចរ។
- រីឯការអភិវឌ្ឍសកម្មភាពអាជីវកម្មទេសចរណ៍ក្នុងរមណីយដ្ឋានអេកូទេសចរណ៍នីមួយៗ មានអ្នកវិនិយោគអេកូទេសចរណ៍ **ប្រតិបត្តិករអេកូទេសចរណ៍** (Eco-Tourism Investor) ដែលសំដៅដល់បុគ្គលជារូបវន្តបុគ្គល ដែលទទួលសិទ្ធិអាជីវកម្មពីអ្នកអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍។

### ៥.២- ការកសាងសមត្ថភាព (Capacity Building)

(២៩). កម្មវិធីបណ្តុះបណ្តាល កសាងសមត្ថភាព និងការបង្កើនការយល់ដឹងអំពីគោលការណ៍សំខាន់ៗនៃការអភិវឌ្ឍអេកូទេសចរណ៍ ត្រូវផ្តោតលើ៖

- ការរៀបចំបណ្តុះបណ្តាលសម្រាប់អ្នករៀបចំផែនការនិងគោលនយោបាយ ជាពិសេស រៀបចំបណ្តុះបណ្តាលមន្ត្រីជំនាញរបស់ក្រសួងទេសចរណ៍ ក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍
- ការរៀបចំបណ្តុះបណ្តាលសម្រាប់អ្នកគ្រប់គ្រងតំបន់ការពារនិងអ្នកល្បាតព្រៃឱ្យយល់ដឹងអំពីសារៈសំខាន់ផ្នែកអេកូទេសចរណ៍ ការគ្រប់គ្រងគោលដៅទេសចរណ៍និងភ្ញៀវទេសចរ ការគ្រប់គ្រងជម្លោះ ការយល់ដឹងអំពីវប្បធម៌ និងបច្ចេកទេសក្នុងការទំនាក់ទំនងសង្គ្រោះបឋម។ល។
- ការរៀបចំការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍សហគមន៍ដល់ប្រជាសហគមន៍
- ការពង្រឹងសមត្ថភាពដល់បណ្តាញសហគមន៍អេកូទេសចរណ៍នៅកម្ពុជា
- ការរៀបចំនិងតាក់តែងផែនការការងារនិងឯកសារសម្រាប់ការបណ្តុះបណ្តាល កសាង សមត្ថភាព និងការបង្កើនការយល់ដឹងជាសាធារណៈអំពីអេកូទេសចរណ៍
- ការបង្កើតវេទិកាថ្នាក់ជាតិអេកូទេសចរណ៍ដែលនឹងធ្វើជារៀងរាល់ឆ្នាំដើម្បីពង្រឹងការផ្លាស់ប្តូរនិងការផ្សព្វ-ផ្សាយបទពិសោធ ចំណេះដឹង ចំណេះធ្វើ ជំនាញឯកទេសថ្មីៗ និងផលិតផលថ្មីក្នុងវិស័យអេកូទេសចរណ៍។

### ៥.៣- យន្តការគាំទ្រហិរញ្ញវត្ថុ

(៣០). យន្តការហិរញ្ញវត្ថុ គឺជាកត្តាគន្លឹះក្នុងការអនុវត្តគោលនយោបាយជាតិអេកូទេសចរណ៍។ ថវិកាអាចបានមកពីប្រភពថវិការដ្ឋ ប្រភពហិរញ្ញប្បទានសហប្រតិបត្តិការ ប្រភពហិរញ្ញប្បទានមកពីវិស័យឯកជនតាមរយៈការលើកទឹកចិត្តឱ្យមានការវិនិយោគលើសកម្មភាពអេកូទេសចរណ៍ ដែលយន្តការនេះនឹងត្រូវលំអិតក្នុងអនុក្រឹត្យស្តីពីការចាត់ចែងនិងការគ្រប់គ្រងមូលនិធិអេកូទេសចរណ៍។

### ៥.៤- ការរៀបចំក្របខណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

(៣១). ការអនុវត្តគោលនយោបាយជាតិអេកូទេសចរណ៍ គឺជាយុទ្ធសាស្ត្រគន្លឹះក្នុងការចូលរួមសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០៣០(SDGs)របស់អង្គការសហប្រជាជាតិ សំដៅចូលរួមដល់ការអភិវឌ្ឍប្រកបដោយបរិយាបន្ន ធ្វើឱ្យជីវភាពប្រជាពលរដ្ឋកម្ពុជាកាន់តែប្រសើរឡើង និងចូលរួមដល់កិច្ចគាំពារបរិស្ថាន ជីវៈចម្រុះ និងអភិរក្សព្រៃឈើឱ្យបានគង់វង្សសម្រាប់បច្ចុប្បន្ននិងអនាគត។ ក្របខណ្ឌច្បាប់និងបទដ្ឋានគតិយុត្តមួយចំនួនបានអនុម័តជាបន្តបន្ទាប់ រួមមានច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីសម្បទាន ច្បាប់ស្តីពីវិនិយោគ ច្បាប់ស្តីពីជលផល។ល។

(៣២). ទន្ទឹមនឹងនោះ ក៏ត្រូវសិក្សា ចងក្រង និងពិនិត្យឡើងវិញនូវបទបញ្ញត្តិនានាដែលទាក់ទងនឹងការអភិវឌ្ឍអេកូ-ទេសចរណ៍នៅកម្ពុជា ដែលមានចែងនៅក្នុងលិខិតបទដ្ឋានជាធរមាន។

(៣៣). ដើម្បីគាំទ្រនិងណែនាំការអនុវត្តឱ្យបានសមស្របតាមស្មារតីនៃគោលនយោបាយជាតិនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនត្រូវកសាង ដូចខាងក្រោម៖

១- ច្បាប់ស្តីពីអេកូទេសចរណ៍

២- ច្បាប់ស្តីពីការបង្កើតតំបន់ទេសចរណ៍ពិសេស

៣- អនុក្រឹត្យស្តីពីការចាត់ចែងនិងគ្រប់គ្រងមូលនិធិអេកូទេសចរណ៍

៤- អនុក្រឹត្យស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

៥- សេចក្តីសម្រេចរាជរដ្ឋាភិបាលកម្ពុជាស្តីពីគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍអេកូទេសចរណ៍កម្ពុជា

៦- រៀបចំឱ្យមានបទដ្ឋានគតិយុត្តបំពេញបន្ថែមនិងការណែនាំលំអិតអំពីនីតិវិធីសម្រាប់ការអនុវត្តផ្សេងៗ។

(៣៤). តាមរយៈការអនុវត្តនូវក្របខណ្ឌច្បាប់និងបទដ្ឋានគតិយុត្តដូចមានរៀបរាប់ខាងលើនេះ ឯកសារនិងស្តង់ដានានាត្រូវរៀបចំឡើង ដែលមានជាអាទិ៍ផែនការអភិវឌ្ឍអេកូទេសចរណ៍ ស្តង់ដាសហគមន៍ទេសចរណ៍ អេកូឡាបិលសម្រាប់រមណីយដ្ឋានអេកូទេសចរណ៍ គោលការណ៍ណែនាំស្តីពីការអភិវឌ្ឍអេកូទេសចរណ៍ បទដ្ឋាន និងស្តង់ដាសំណង់ក្នុងរមណីយដ្ឋានអេកូទេសចរណ៍ យន្តការត្រួតពិនិត្យការអភិវឌ្ឍអេកូទេសចរណ៍។ល។ ម៉្យាងទៀតដើម្បីគាំទ្រដល់សហគមន៍មូលដ្ឋានមានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងការអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ ត្រូវផ្តល់**បុគ្គលភាពគតិយុត្ត**ដល់សហគមន៍ទាំងនេះ ដោយតម្រូវឱ្យមានការបង្កើតនូវបទដ្ឋានគតិយុត្តបំពេញបន្ថែម និងយន្តការទទួលស្គាល់សហគមន៍ដែលកំពុងដំណើរការ និងយន្តការទទួលស្គាល់ការបង្កើតសហគមន៍ទេសចរណ៍អេកូទេសចរណ៍នៅក្នុងតំបន់ការពារធម្មជាតិ។

### ៥.៥- ដំណើរការអនុវត្តគោលនយោបាយ

(៣៥). ដើម្បីអនុវត្តគោលនយោបាយជាតិអេកូទេសចរណ៍នេះ ប្រកបដោយប្រសិទ្ធភាព ការបង្កើតស្ថាប័នថ្នាក់ជាតិមួយ គឺជាកត្តាសំខាន់ក្នុងការឈានទៅសម្រេចតាមគោលបំណង និងចក្ខុវិស័យដែលបានកំណត់ទុក។ ក្នុងន័យនេះ ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍នឹងក្លាយទៅជាអង្គភាពទទួលបន្ទុក លើរាល់ដំណើរការនៃការអនុវត្តគោលនយោបាយជាតិអេកូទេសចរណ៍។ ទន្ទឹមនឹងនេះ ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់អង្គភាពនេះពីរាជរដ្ឋាភិបាល រួមទាំងមូលនិធិអេកូទេសចរណ៍ ហិរញ្ញប្បទានសហប្រតិបត្តិការ និងជំនួយបច្ចេកទេសផ្សេងៗ គឺជាកម្លាំងចលករជំរុញឱ្យការអនុវត្តគោលនយោបាយជាតិអេកូទេសចរណ៍ទទួលបានជោគជ័យ។ ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយពីគោលនយោបាយនេះដល់គ្រប់ភាគីពាក់ព័ន្ធ ទាំងផ្នែកសាធារណៈ ផ្នែកឯកជន សហគមន៍មូលដ្ឋាន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍនានា ដើម្បីធានានិរន្តរភាពនៃការអភិវឌ្ឍវិស័យអេកូទេសចរណ៍នៅកម្ពុជា។

## ៦- ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ

(៣៦). ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ត្រូវបង្កើតយន្តការដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្រ្ត និងផែនការសកម្មភាពអេកូទេសចរណ៍។ យន្តការទាំងនេះ រួមមាន ការបង្កើតសូចនាករសំខាន់ៗមួយចំនួន ដើម្បីវាយតម្លៃលើការអនុវត្តគម្រោងអភិវឌ្ឍអេកូទេសចរណ៍ទាំងខ្នាតធំនិងខ្នាតតូច ការធ្វើរបាយការណ៍លទ្ធផលការងារដែលអនុវត្តបាន និងការធ្វើបច្ចុប្បន្នកម្មលើទិសដៅ និងគោលដៅដែលមានចែងក្នុងផែនការសកម្មភាពអភិវឌ្ឍអេកូទេសចរណ៍។ ដំណើរការត្រួតពិនិត្យនេះនឹងត្រូវសម្របសម្រួលដោយការបង្កើតនូវគោលការណ៍ណែនាំជាច្រើន ដូចជាគោលការណ៍ណែនាំសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ជាអាទិ៍ ការអង្កេតពីផលប្រយោជន៍សេដ្ឋកិច្ច-សង្គមរបស់គម្រោងអភិវឌ្ឍអេកូទេសចរណ៍និងផលប្រយោជន៍ផ្នែកបរិស្ថានដល់ការអភិរក្សធនធានធម្មជាតិ ការអង្កេតអំពីចំនួនភ្ញៀវចូលទស្សនា និងសមត្ថភាពផ្ទុករបស់រមណីយដ្ឋានអេកូទេសចរណ៍នីមួយៗ ការធ្វើអធិការកិច្ចផ្នែក

បរិស្ថាន-សង្គមនៅតាមរមណីយដ្ឋានអេកូទេសចរណ៍នីមួយៗ ការរៀបចំអេកូឡាបិលសម្រាប់រមណីយដ្ឋានអេកូទេសចរណ៍ការរីកចម្រើនហេដ្ឋារចនាសម្ព័ន្ធនៅតាមរមណីយដ្ឋានអេកូទេសចរណ៍ជាដើម។

**(៣៧).** លទ្ធផលចេញពីការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ នឹងក្លាយជាត្រីវិស័យសម្រាប់រៀបចំកែលម្អយុទ្ធសាស្ត្រ និងផែនការសកម្មភាពអភិវឌ្ឍអេកូទេសចរណ៍។

## ៧- សេចក្តីសន្និដ្ឋាន

**(៣៨).** វិស័យទេសចរណ៍ត្រូវបានចាត់ទុកថាជាអន្តរវិស័យមួយដែលមិនត្រឹមតែអាចចូលរួមដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាផ្នែកមួយដែលចូលរួមយ៉ាងសកម្មដល់កិច្ចការពារបរិស្ថាន ពិសេសរួមចំណែកទប់ទល់នឹងបញ្ហាបម្រែបម្រួលអាកាសធាតុ ដែលជាបញ្ហាប្រឈមជាសកលមួយសម្រាប់ពិភពលោកនាពេលបច្ចុប្បន្ន។ អេកូទេសចរណ៍ គឺជាធាតុគន្លឹះចូលរួមយ៉ាងមានប្រសិទ្ធភាពដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ។

**(៣៩).** ដូច្នេះ ការរៀបចំគោលនយោបាយជាតិអេកូទេសចរណ៍របស់រាជរដ្ឋាភិបាលនឹងចូលរួមយ៉ាងសកម្មដល់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលនិងគោលនយោបាយជាតិស្តីពីទេសចរណ៍កម្ពុជាក្នុងការធ្វើឱ្យកម្ពុជាក្លាយជាគោលដៅទេសចរណ៍ប្រកបដោយគុណភាពលំដាប់ពិភពលោក ផ្តល់ភាពកក់ក្តៅដល់ទេសចរ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ ក៏ដូចជាឆ្លើយតបនឹងផែនការយុទ្ធសាស្ត្រទេសចរណ៍អាស៊ាន២០១៦-២០២៥ ក្នុងការប្រែក្លាយតំបន់អាស៊ានជាគោលដៅទេសចរណ៍ប្រកបដោយគុណភាព ផ្តល់ជូននូវបទពិសោធទោលដែលមានភាពចម្រុះគ្នាដល់ភ្ញៀវទេសចរ។ ម្យ៉ាងទៀត គោលនយោបាយជាតិអេកូទេសចរណ៍នេះនឹងចូលរួមគាំទ្រដល់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍កម្ពុជា(២០១២-២០២០) ក្នុងការធ្វើឱ្យវិស័យទេសចរណ៍ក្លាយជា **"មាសបៃតង"** តាមរយៈការធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពប្រជាពលរដ្ឋ ចូលរួមដល់ការអភិរក្សធនធានធម្មជាតិនិងកិច្ចគាំពារបរិស្ថាន ពិសេស គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការគាំពារនិងអភិរក្សធនធានធម្មជាតិឱ្យមានប្រសិទ្ធភាពខ្ពស់សម្រាប់ប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ននិងអនាគតដែលជាការគាំទ្រដល់ការចូលរួមសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ(UN)។ **"គោលនយោបាយជាតិអេកូទេសចរណ៍"** ដែលបានរៀបចំឡើងដោយមានការចូលរួមប្រកបដោយភាពសុខដុមរមនារវាងគ្រប់វិស័យពាក់ព័ន្ធ អមដោយយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគ្រប់ជ្រុងជ្រោយលើរាល់គម្រោងអភិវឌ្ឍអេកូទេសចរណ៍ គឺជាឧបករណ៍ដ៏មានសារៈសំខាន់ ចូលរួមដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងធានាដល់ការបែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌សម្រាប់គ្រប់ភាគីពាក់ព័ន្ធនាពេលបច្ចុប្បន្ន និងសម្រាប់កូនចៅជំនាន់ក្រោយនាពេលអនាគតផងដែរ។

**(៤០).** **"គោលនយោបាយជាតិអេកូទេសចរណ៍"** ជាផែនទីចង្អុលផ្លូវសម្រាប់ដឹកនាំវិស័យសាធារណៈ ឯកជន និងសហគមន៍ ចូលរួមធ្វើឱ្យសម្រេចបានកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។

## សន្ទានុក្រម

**ទេសចរណ៍** សំដៅដល់សកម្មភាពទាំងឡាយរបស់បុគ្គលដែលធ្វើដំណើរទៅនិងស្នាក់នៅកន្លែងផ្សេង ក្រៅពីបរិយាកាសប្រក្រតីរបស់គេ សម្រាប់រយៈពេលកំណត់មួយ ដែលមិនលើសពីមួយឆ្នាំជាប់ៗគ្នា ដើម្បីសម្រាក លំហែកម្សាន្ត ធ្វើធុរកិច្ច និងមានគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត។

**ទេសចរ** សំដៅដល់ជនជាតិកម្ពុជាឬជនបរទេសទាំងឡាយដែលមកដល់តំបន់ផ្សេង ក្រៅពីបរិយាកាសប្រក្រតីរបស់គេ ស្នាក់នៅទីនោះចាប់ពីមួយយប់ឡើងទៅ និងមិនលើសពីរយៈពេលដែលកំណត់ដើម្បីសម្រាក លំហែកម្សាន្ត ធ្វើធុរកិច្ច និងមានគោលបំណងទេសចរណ៍ស្របច្បាប់ផ្សេងៗទៀត ព្រមទាំងមិនទាក់ទងដល់គោលបំណងតាំងទីលំនៅឬធ្វើសកម្មភាពណាមួយដែលទទួលបានប្រាក់កម្រៃនៅទីនោះ។

**តំបន់អេកូទេសចរណ៍** សំដៅដល់តំបន់ទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា(បច្ចុប្បន្នមាន ៤តំបន់អាទិភាព) ដែលត្រូវបានជ្រើសរើស រៀបចំ និងអភិវឌ្ឍបម្រើឱ្យគោលបំណងនិងសកម្មភាពអេកូទេសចរណ៍។

**អេកូទេសចរណ៍** សំដៅដល់ទម្រង់ទេសចរណ៍ ផ្អែកលើធម្មជាតិដែលមានគោលបំណងអភិរក្សបរិស្ថានធម្មជាតិ និងវប្បធម៌ តំបន់ជួយលើកកម្ពស់ជីវភាពរស់នៅ សុខុមាលភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន ផ្តល់បទពិសោធល្អដល់ទេសចរ និងការធ្វើដំណើរប្រកបដោយការទទួលខុសត្រូវ និងកម្សាន្ត កោតសរសើរ រៀនសូត្រពីធម្មជាតិ។

**រមណីយដ្ឋានអេកូទេសចរណ៍** សំដៅកន្លែងស្ថិតក្នុងតំបន់អេកូទេសចរណ៍ ដែលត្រូវបានជ្រើសរើស រៀបចំ និងអភិវឌ្ឍបម្រើឱ្យគោលបំណងនិងសកម្មភាពអេកូទេសចរណ៍រាប់បញ្ចូលរាល់សកម្មភាពទាំងឡាយដែលបំពេញតម្រូវការភ្ញៀវទេសចរនៅក្នុងរមណីយដ្ឋានអេកូទេសចរណ៍។ រមណីយដ្ឋានអេកូទេសចរណ៍មាន**២ប្រភេទ** គឺខ្នាតតូច (សហគមន៍ទេសចរណ៍មូលដ្ឋាន) និងខ្នាត់ធំ (គម្រោងអភិវឌ្ឍអេកូទេសចរណ៍របស់វិស័យឯកជន)។

**សហគមន៍ទេសចរណ៍មូលដ្ឋាន** សំដៅដល់ទីតាំងឬកន្លែងទាក់ទាញទេសចរណ៍ដែលរៀបចំឡើងដោយសហគមន៍មូលដ្ឋានខ្លួនឯងផ្ទាល់ឬដោយមានកិច្ចសហប្រតិបត្តិការ ដើម្បីពង្រឹងកិច្ចអភិវឌ្ឍមូលដ្ឋានក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយជីវភាពរស់នៅរបស់សហគមន៍ និងបម្រើផលប្រយោជន៍ប្រជាពលរដ្ឋមូលដ្ឋាន តាមរយៈការអភិវឌ្ឍអេកូទេសចរណ៍ប្រកបដោយនិរន្តរភាព។

**គំរូនៃការអភិវឌ្ឍអេកូទេសចរណ៍(ខ្នាតតូច)** សំដៅលើការអភិវឌ្ឍអេកូទេសចរណ៍ផ្អែកលើសហគមន៍ដែលផ្តល់ឱកាសឱ្យប្រជាជននិងសហគមន៍មូលដ្ឋានទទួលបានផលប្រយោជន៍ដោយផ្ទាល់ពីផ្នែកអេកូទេសចរណ៍ និងចូលរួមថែរក្សានិងអភិរក្សធនធានធម្មជាតិក្នុងតំបន់របស់ពួកគេ។

**គំរូនៃការអភិវឌ្ឍអេកូទេសចរណ៍(ខ្នាតធំ)** សំដៅលើការអភិវឌ្ឍអេកូទេសចរណ៍តាមរយៈគម្រោងវិនិយោគធំៗ ដែលប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយដោយគោរពតាមបទដ្ឋានបរិស្ថាន-សង្គម។

**អេកូឡាបិល** សំដៅដល់ស្លាកសញ្ញាបរិស្ថានពិសេស ដែលកំណត់ដោយច្បាប់ទេសចរណ៍ ក្រោមមាត្រា២៧ សម្រាប់ផលិតផលអេកូទេសចរណ៍។

**ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត** សំដៅដល់ អាគារ ផ្លូវថ្នល់ មន្ទីរពេទ្យ។ល។

**ហេដ្ឋារចនាសម្ព័ន្ធទន់ (ឬអរូបី)** សំដៅដល់ការអប់រំបណ្តុះបណ្តាល ការកសាង និងពង្រឹងសមត្ថភាពការបញ្ជ្រាបការយល់ដឹង។ល។

**អ្នកអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍** សំដៅដល់អ្នកទទួលបានសិទ្ធិអភិវឌ្ឍពីរាជរដ្ឋាភិបាលកម្ពុជាលើការអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍កម្ពុជា (ខ្នាតតូច ឬខ្នាតធំ)។

**ប្រតិបត្តិករអេកូទេសចរណ៍** សំដៅដល់វិនិយោគិនដែលទទួលបានសិទ្ធិប្រកបអាជីវកម្មទេសចរណ៍នៅក្នុងរមណីយដ្ឋានអេកូទេសចរណ៍ក្រោមកិច្ចព្រមព្រៀងជាមួយអ្នកអភិវឌ្ឍរមណីដ្ឋានអេកូទេសចរណ៍(ដូចជាម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កីឡាទេសចរណ៍ផ្សេងៗជាដើម)។

# ឧបសម្ព័ន្ធ : តារាងវិធានការគោលនយោបាយ

| ទិសដៅជាយុទ្ធសាស្ត្រ | យុទ្ធសាស្ត្រ | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
|---|---|---|---|
| **៤.១- ធ្វើផែនការនិងបែងចែកជាតំបន់អេកូទេសចរណ៍អាទិភាពនិងរៀបចំរមណីដ្ឋានអេកូទេសចរណ៍គំរូ** | | | |
| **យុទ្ធសាស្ត្រក្នុងការធ្វើផែនការនិងបែងចែកជាតំបន់អាទិភាព និងការរៀបចំរមណីយដ្ឋានអេកូទេសចរណ៍រួមមាន៖** | - កំណត់អត្តសញ្ញាណកម្ម (Mapping) រមណីយដ្ឋានអេកូទេសចរណ៍នៅតាមតំបន់អាទិភាពនីមួយៗ | ២០១៩-២០២១ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | - រៀបចំអភិវឌ្ឍជារមណីយដ្ឋានអេកូទេសចរណ៍គំរូយ៉ាងហោចមួយ នៅតាមតំបន់អាទិភាពនីមួយៗដែលអាចបម្រើឱ្យភ្ញៀវទេសចរស្នាក់នៅរយៈពេលខ្លី មធ្យម និងវែង (ទេសចរផ្ទះទីពីរ) | ២០១៩-២០២២ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | - តម្រូវឱ្យមានផែនការមេអភិវឌ្ឍអេកូទេសចរណ៍ សម្រាប់គម្រោងអភិវឌ្ឍអេកូទេសចរណ៍នីមួយៗ ដោយត្រូវគិតគូរអំពីការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុផង និងឆ្លើយតបតម្រូវការចាំបាច់នៃការអភិវឌ្ឍឱ្យបានជាអតិបរមាផង ស្របតាមគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍអេកូទេសចរណ៍ | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| | - រៀបចំឱ្យមានមូលនិធិទ្រទ្រង់ដល់ការសិក្សារៀបចំគម្រោងអេកូទេសចរណ៍ក្នុងដំណាក់កាលសមិទ្ធិលទ្ធភាព | ២០១៩-២០២០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | - រៀបចំបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងលើការតុបតែងរចនា ការស្ថាបនា និងប្រតិបត្តិការ (DBO) នៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សម្បទា និងសេវាកម្មទេសចរណ៍ចាំបាច់នានាក្នុងរមណីយដ្ឋានអេកូទេសចរណ៍ | ២០១៩-២០២០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |
| **៤.២- ការបង្កើនលទ្ធភាពធ្វើអាជីវកម្ម និងវិនិយោគទេសចរណ៍ក្នុងរមណីយដ្ឋានអេកូទេសចរណ៍** | | | |
| **យុទ្ធសាស្ត្រក្នុងការបង្កើនលទ្ធភាពធ្វើអាជីវកម្មនិងវិនិយោគទេសចរណ៍រួមមាន៖** | - ធានាឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាពនិងការទទួលខុសត្រូវខ្ពស់ក្នុងតំបន់ការពារធម្មជាតិគម្រោងអភិវឌ្ឍអេកូទេសចរណ៍ ដោយផ្ដល់លក្ខណសម្បត្តិការអភិវឌ្ឍគម្រោងអេកូទេសចរណ៍ជាតំបន់ទេសចរណ៍ពិសេស | ២០១៩-២០២០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ត្រូវរៀបចំគោលការណ៍ណែនាំច្បាស់លាស់សម្រាប់រាល់ទម្រង់នៃជម្រើសជាយុទ្ធសាស្ត្រចំពោះការអនុវត្ត គម្រោងអភិវឌ្ឍអេកូទេសចរណ៍ខ្នាតតូចនិងខ្នាតធំ ព្រមទាំងកំណត់លក្ខណវិនិច្ឆ័យសម្រាប់រៀបចំប្លង់មេអភិវឌ្ឍគ្រប់គម្រោងអេកូទេសចរណ៍ | ២០១៩-២០២០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |

| | | | |
|---|---|---|---|
| | - បង្កើតនូវប្រភេទមូលនិធិបរធនបាលកិច្ច(Trust Fund) សម្រាប់គាំទ្រគម្រោងអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍(ខ្នាតតូចនិងខ្នាតធំ) | ២០១៩-២០២០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- គណៈកម្មការមូលបត្រកម្ពុជា<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | - បង្កើតគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍអេកូទេសចរណ៍ | ២០១៩-២០២០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | - រៀបចំប្រព័ន្ធហិរញ្ញប្បទានអនុគ្រោះ ដើម្បីផ្តល់កម្ចីដល់ប្រតិបត្តិករទេស-ចរណ៍ ដែលមានអាជីវកម្មក្នុងរមណីយដ្ឋានអេកូទេសចរណ៍ | ២០១៩-២០២០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ធនាគារជាតិកម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- គណៈកម្មការមូលបត្រកម្ពុជា<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| | - ពង្រឹងសមត្ថភាពហិរញ្ញវត្ថុនិងបច្ចេកទេសក្នុងការធ្វើអាជីវកម្មនិងវិនិយោគក្នុងរមណីយដ្ឋានអេកូទេសចរណ៍ តាមរយៈការបង្កើតក្លឹបអ្នកវិនិយោគក្នុងវិស័យទេសចរណ៍ និងបណ្តាញសហគមន៍ទេសចរណ៍/អេកូទេសចរណ៍កម្ពុជា | ២០១៩-២០២០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | - បង្កើតយន្តការគាំទ្រសមត្ថភាពហិរញ្ញវត្ថុនិងបច្ចេកទេសដល់ប្រតិបត្តិករទេសចរណ៍ជាសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម ដែលធ្វើអាជីវកម្មក្នុងរមណីយដ្ឋានអេកូទេសចរណ៍ សំដៅពង្រឹងគុណភាព និងពង្រីកសេវាកម្មទេសចរណ៍ក្នុងរមណីយដ្ឋានទេសចរណ៍ | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |
| **៤.៣. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (រូបវន្តនិងទន់) និងការវិភាគសមត្ថភាពផ្ទុកក្នុងរមណីយដ្ឋានអេកូទេសចរណ៍** | | | |
| **៤.៣.១. យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទន់:** | - ពង្រឹងសមត្ថភាពដល់អ្នកសម្រេចចិត្តនិងអ្នកអនុវត្តគោលនយោបាយជាតិអេកូទេសចរណ៍ | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | - ផ្តល់ការបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពដល់អ្នកអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ និងផ្តល់ការទទួលស្គាល់ ជាប្រតិបត្តិករ ដែលមានប្រវត្តិនិងស្នាដៃខាងបរិស្ថាន និងសង្គម (ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍) | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | - ពិនិត្យ សិក្សា ធ្វើបច្ចុប្បន្នកម្ម និងកសាងបទដ្ឋានគតិយុត្តចាំបាច់នានាដែលទាក់ទងនឹងសកម្មភាពអេកូទេសចរណ៍ | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ |

| | | | |
|---|---|---|---|
| | | | - ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | - បណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍នៅក្នុងរមណីយដ្ឋានអេកូទេសចរណ៍ | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ជំរុញរៀបចំវគ្គសិក្សាកម្រិតឧត្តមសិក្សានិងថ្នាក់ជំនាញវិជ្ជាជីវៈផ្នែកអេកូ-ទេសចរណ៍នៅតាមគ្រឹះស្ថានឧត្តមសិក្សា និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |
| | - រៀបចំក្រុមបណ្តុះបណ្តាលជំនាញចល័ត ដើម្បីធ្វើការសម្របសម្រួលនិងអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលឱ្យមានលក្ខណៈស្តង់ដា និងរៀបចំឯកសារសិក្សាសម្រាប់សហគមន៍ និងប្រជាពលរដ្ឋមូលដ្ឋាន | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| **៤.៣.២. យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត៖** | - ត្រូវកសាងផ្លូវចូលឆ្ពោះទៅកាន់រមណីយដ្ឋានអេកូទេសចរណ៍ឱ្យបានគ្រប់គ្រាន់ | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងអភិវឌ្ឍន៍ជនបទ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ជំរុញនិងលើកទឹកចិត្តឲ្យកសាងហេដ្ឋារចនាសម្ព័ន្ធដែលអាចមានឥទ្ធិពលអវិជ្ជមានតិចតួចដល់បរិស្ថាន វប្បធម៌ ដោយត្រូវគិតគូរលើរចនាបទអាគារគំរូស្ថាបត្យកម្មជាក់លាក់ និងគោរពវប្បធម៌នៅតាមមូលដ្ឋាន (ដូចជាអេកូឡូច) | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ |

| | | | |
|---|---|---|---|
| | ដោយទប់ស្កាត់ការសាងសង់សំណង់ធំៗក្នុងតំបន់អភិរក្សនិងតំបន់ការពារធម្មជាតិនានា | | - ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ត្រូវកសាងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដូចជាស្លាកសញ្ញាសំគាល់សម្រាប់ភ្ញៀវ ផ្លូវដើរទស្សនា ធុងសំរាម ដែលមានការបែងចែកត្រឹមត្រូវ មណ្ឌលព័ត៌មានទេសចរណ៍ សារមន្ទីរ ផែនទី ស្លាកសញ្ញាផ្តល់ព័ត៌មានបង្ហាញពីផ្លូវធ្វើដំណើរក្នុងព្រៃ បង្គន់ និងកន្លែងទស្សនានៅរមណីយដ្ឋានអេកូទេសចរណ៍ | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញ ក្នុងគោលបំណងបម្រើឱ្យសកម្មភាពទេសចរណ៍នៅរមណីយដ្ឋានអេកូទេសចរណ៍ | ២០១៩-២០៣០ | - ក្រសួងបរិស្ថាន<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ជំរុញការប្រើប្រាស់សេវាដឹកជញ្ជូនដែលគោរពតាមស្តង់ដាបរិស្ថានក្នុងរមណីយដ្ឋានអេកូទេសចរណ៍ | ២០១៩-២០៣០ | - ក្រសួងបរិស្ថាន<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| **៤.៤. ការអភិវឌ្ឍនិងពង្រឹងគុណភាពសេវាកម្មទេសចរណ៍ក្នុងរមណីយដ្ឋានអេកូទេសចរណ៍** | | | |
| **យុទ្ធសាស្ត្រក្នុងការអភិវឌ្ឍនិងពង្រឹងគុណភាពសេវាកម្មទេសចរណ៍ក្នុងរមណីយដ្ឋានអេកូទេសចរណ៍:** | - ធ្វើអធិការកិច្ចផ្នែកបរិស្ថានឱ្យបានទៀងទាត់លើរាល់ការអនុវត្តរបស់ប្រតិបត្តិករទេសចរណ៍ នានា ក្នុងរមណីយដ្ឋានអេកូទេសចរណ៍ | ២០១៩-២០៣០ | - ក្រសួងបរិស្ថាន<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ពង្រឹងគុណភាពនៃការអភិវឌ្ឍរមណីយដ្ឋានអេកូទេសចរណ៍ខ្នាតតូចឱ្យស្របតាមស្តង់ដាសហគមន៍ទេសចរណ៍កម្ពុជា | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |

| | | | |
|---|---|---|---|
| | - បង្កើតឱ្យមានស្តង់ដា សូចនាករ និង/ឬគោលការណ៍ណែនាំផ្នែកបរិស្ថាន និងសង្គមឱ្យបានលំអិតសម្រាប់ប្រតិបត្តិការ និងអាជីវកម្មក្នុងរមណីយដ្ឋានអេកូទេសចរណ៍ | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - កសាងនិងពង្រឹងសមត្ថភាពមគ្គុទ្ទេសក៍ទេសចរណ៍ ក្នុងរមណីយដ្ឋានអេកូ-ទេសចរណ៍(មគ្គុទ្ទេសក៍ទេសចរណ៍សហគមន៍) ដើម្បីធានាដល់ការផ្តល់ព័ត៌មានច្បាស់លាស់ប្រកបដោយគុណភាពដល់ភ្ញៀវទេសចរ | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ប្រតិបត្តិករអេកូទេសចរណ៍ ដែលធ្វើអាជីវកម្មក្នុងរមណីយដ្ឋានអេកូទេស-ចរណ៍ត្រូវគោរពតាមស្តង់ដា និងគោលការណ៍ណែនាំនានា ផ្នែកបរិស្ថាន និងសង្គម ត្រូវធ្លាប់ទទួលបានជ័យលាភី **រង្វាន់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍** | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - អភិវឌ្ឍនិងជំរុញការលក់វត្ថុអនុស្សាវរីយ៍ដែលផលិតនៅក្នុងសហគមន៍ (មានការគិតគូរលើវប្បធម៌ ប្រពៃណី និងធានាថាមានឥទ្ធិពលអប្បបរមាលើធនធានធម្មជាតិ) ដល់ភ្ញៀវទេសចរ និងផ្គត់ផ្គង់ផលិតផលសរីរាង្គដល់ភ្ញៀវទេសចរ | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ពង្រឹងនិងពង្រីកសកម្មភាពអេកូទេសចរណ៍ ដូចជាការទស្សនាសត្វស្លាបថនិកសត្វ សត្វចតុប្បាទ ការថតទេសភាព ខ្សែទស្សនកិច្ចស្វែងយល់ពីប្រពៃណីនិងធម្មជាតិ របាំ ការជិះកង់ ដំណើររុករកក្នុងព្រៃ ឡើងភ្នំ ជាដើម | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |

| | | | |
|---|---|---|---|
| | - រៀបចំមណ្ឌលព័ត៌មានទេសចរណ៍នៅតាមរមណីយដ្ឋានអេកូទេសចរណ៍នីមួយៗ | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - រៀបចំពិធីបុណ្យដែលផ្សារភ្ជាប់នឹងការអភិរក្សធនធានធម្មជាតិនិងជីវៈចម្រុះ ដូចជាពិធីបុណ្យសមុទ្រ បុណ្យទន្លេ បុណ្យទស្សនាសត្វស្លាប បុណ្យបំបួសដើមឈើជាដើម | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ពង្រឹងគុណភាពសេវាកម្មផ្ទះស្នាក់នៅតាមសហគមន៍ ឱ្យស្របតាមស្តង់ដាផ្ទះស្នាក់កម្ពុជា ពិសេសឆ្លើយតបនឹងតម្រូវការរបស់ភ្ញៀវទេសចរ (ដូចជាបន្ទប់ទឹក បង្គន់ បន្ទប់ស្នាក់ សេវាផ្សេងៗជាដើម) | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ធានាឱ្យមានតម្លាភាពក្នុងការកំណត់តម្លៃសេវាកម្មក្នុងរមណីយដ្ឋានអេកូ-ទេសចរណ៍ | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - រៀបចំឱ្យមាន Eco-Certification សម្រាប់អាជីវកម្មនៅតាមរមណីយដ្ឋានអេកូទេសចរណ៍ | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - បង្កើតកម្មវិធី “**ពានរង្វាន់អេកូទេសចរណ៍កម្ពុជា**” ប្រចាំឆ្នាំដើម្បីទទួលស្គាល់និងលើកទឹកចិត្តដល់អ្នកអនុវត្តល្អៗ (ប្រតិបត្តិករទេសចរណ៍ សហគមន៍ និងអ្នកផ្គត់ផ្គង់សេវា។ល។) ក្នុងការអភិវឌ្ឍអេកូទេសចរណ៍នៅតាមគោលដៅនីមួយៗ | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| **៤.៥. ការសិក្សាទីផ្សារនិងផ្សព្វផ្សាយអេកូទេសចរណ៍** | | | |

| | | | |
|---|---|---|---|
| **យុទ្ធសាស្ត្រក្នុងការសិក្សាទីផ្សារនិងផ្សព្វផ្សាយអេកូទេសចរណ៍ រួមមាន :** | - ជំរុញការផ្សព្វផ្សាយអេកូទេសចរណ៍ទៅកាន់ទីផ្សារអន្តរជាតិ | **២០១៩-២០៣០** | - ក្រសួងទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - រៀបចំយុទ្ធសាស្ត្រសិក្សាទីផ្សារនិងផ្សព្វផ្សាយសម្រាប់អេកូទេសចរណ៍កម្ពុជា | **២០១៩-២០៣០** | - ក្រសួងទេសចរណ៍<br>- ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - បង្កើតវេទិការួមដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន សហគមន៍ទេសចរណ៍ អង្គការជាតិ និងអន្តរជាតិ សម្រាប់ការងារសិក្សាទីផ្សារក្នុងផ្នែកអេកូទេសចរណ៍ | **២០១៩-២០៣០** | - ក្រសួងទេសចរណ៍<br>- ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - បង្កើតទិន្នន័យថ្នាក់ជាតិ ដោយសិក្សាស្រាវជ្រាវ ធ្វើបច្ចុប្បន្នកម្មលើតម្រូវការ និងនិន្នាការនៃទីផ្សារអេកូទេសចរណ៍នៅកម្រិតសកលលោក តំបន់ និងថ្នាក់ជាតិ និងរៀបចំអង្កេត និងធ្វើបច្ចុប្បន្នកម្មទីផ្សារអេកូទេសចរណ៍ ដើម្បីជាមូលដ្ឋានសម្រាប់ការរៀបចំយុទ្ធសាស្ត្រសិក្សាទីផ្សារ និងផ្សព្វផ្សាយអេកូ-ទេសចរណ៍ | **២០១៩-២០៣០** | - ក្រសួងទេសចរណ៍<br>- ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |

| | | | |
|---|---|---|---|
| | - ធ្វើ Branding កម្ពុជាជាគោលដៅអេកូទេសចរណ៍ដ៏ទាក់ទាញ ក្រោមពាក្យស្លោក **"ការស្វែងរកពិភពបៃតង"** ដែលជាផ្នែកមួយនៃ **"កម្ពុជា៖ ព្រះរាជាណាចក្រអច្ឆរិយៈ ផ្តល់ភាពកក់ក្តៅ"** | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ជំរុញការផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យាទំនើប(e-marketing) ដោយរៀបចំជាគេហទំព័រផ្សព្វផ្សាយរួមអំពីអេកូទេសចរណ៍កម្ពុជា (www.Cambodiaecotourism.com) | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ផ្សព្វផ្សាយនិងទាក់ទាញទេសចរកម្រិតខ្ពស់ ទេសចរយុវជន ទេសចរផ្ទះទីពីរ មកកាន់រមណីយដ្ឋានអេកូទេសចរណ៍ | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| **៤.៦. ការធានាសុវត្ថិភាពនៅតាមរមណីយដ្ឋានអេកូទេសចរណ៍** | | | |
| **យុទ្ធសាស្ត្រធានាសុវត្ថិភាពនៅរមណីយដ្ឋានអេកូទេសចរណ៍ រួមមាន៖** | - បណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍នូវចំណេះដឹងសង្គ្រោះបឋម ដើម្បីមានលទ្ធភាពសង្គ្រោះភ្ញៀវនៅពេលមានគ្រោះថ្នាក់ | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងសុខាភិបាល<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - រៀបចំប្រព័ន្ធសន្តិសុខសុវត្ថិភាពទេសចរណ៍(Healthy Tourism System) និងប្រព័ន្ធសង្គ្រោះបន្ទាន់នៅតាមរមណីយដ្ឋានអេកូទេសចរណ៍នីមួយៗ ព្រមទាំងបើកវគ្គបណ្តុះបណ្តាលអំពីប្រព័ន្ធទាំងនេះដល់សហគមន៍ ប្រតិបត្តិករទេសចរណ៍ និងគ្រប់ភាគីពាក់ព័ន្ធដែលធ្វើអាជីវកម្មក្នុងរមណីយដ្ឋានអេកូ-ទេសចរណ៍ | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងសុខាភិបាល<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - រៀបចំផែនទីចង្អុលចំណុច/តំបន់គ្រោះថ្នាក់នៅតាមរមណីយដ្ឋានអេកូ-ទេសចរណ៍នីមួយៗ | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងបរិស្ថាន |

| | | | |
|---|---|---|---|
| | | | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| **៤.៧. ការបញ្ជ្រាបការយល់ដឹងនិងអប់រំអំពីអេកូទេសចរណ៍** | | | |
| **យុទ្ធសាស្ត្រក្នុងការបញ្ជ្រាបការយល់ដឹង និងអប់រំអំពីអេកូ-ទេសចរណ៍រួមមាន៖** | - រៀបចំកម្មវិធីផ្សព្វផ្សាយការយល់ដឹងជាសាធារណៈពីអេកូទេសចរណ៍ដល់គ្រប់ភាគីពាក់ព័ន្ធ | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងព័ត៌មាន<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - លើកកម្ពស់ការយល់ដឹងអំពីទស្សនាទាននៃអេកូទេសចរណ៍ ផលប៉ះពាល់ ផលប្រយោជន៍ កាលានុវត្តភាព និងផលវិបាកនៃការអភិវឌ្ឍអេកូទេសចរណ៍ ដល់រដ្ឋបាលថ្នាក់ក្រោមជាតិមូលដ្ឋាន សិស្ស និស្សិត ប្រជាពលរដ្ឋមូលដ្ឋាន ភ្ញៀវទេសចរ និងគ្រប់ភាគីពាក់ព័ន្ធ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ កម្មវិធីសិក្សា ជាដើម | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - បង្កើនការយល់ដឹងដល់ភ្ញៀវទេសចរអំពីគោលការណ៍របស់អេកូទេសចរណ៍ បទពិសោធល្អៗ និងការប្រតិបត្តិអំពី **"អ្វីដែលគួរធ្វើ"** និង **"អ្វីដែលមិនគួរធ្វើ"** នៅក្នុងរមណីយដ្ឋានអេកូទេសចរណ៍ | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |

| | | | |
|---|---|---|---|
| | - ផ្ដល់ការបណ្ដុះបណ្ដាលនិងពង្រឹងសមត្ថភាពដល់ប្រតិបត្តិករទេសចរណ៍ សហគមន៍ទេសចរណ៍ អាជីវករអេកូទេសចរណ៍ និងភាគីពាក់ព័ន្ធឱ្យយល់ដឹងពីផ្នែកអេកូទេសចរណ៍ (ការផ្សព្វផ្សាយ ការធ្វើផែនការ។ល។) | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ជំរុញឱ្យមានការរៀបចំទស្សនកិច្ចសិក្សាស្វែងយល់ពីធម្មជាតិនៅតាមតំបន់ធម្មជាតិ តំបន់អេកូទេសចរណ៍ដល់កម្មករ បុគ្គលិក សិស្ស និស្សិត និងមន្ត្រីរាជការ (ដោយមានមគ្គុទ្ទេសក៍ទេសចរណ៍មានគុណភាពបកស្រាយពន្យល់) | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- សហភាពសហព័ន្ធយុវជនកម្ពុជា<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - រៀបចំការបណ្ដុះបណ្ដាលសម្រាប់សហគមន៍មូលដ្ឋានអំពីចំណេះដឹងលើវិស័យទេសចរណ៍(ពិសេស ផ្ដោតលើតួនាទីរបស់សហគមន៍ទេសចរណ៍/អេកូទេសចរណ៍) និងការអភិរក្ស របៀបធ្វើអាជីវកម្មបម្រើឱ្យភ្ញៀវទេសចរនៅថ្នាក់មូលដ្ឋាន (ការគ្រប់គ្រងហិរញ្ញកិច្ច ការងារបដិសណ្ឋារកិច្ច មគ្គុទ្ទេសក៍ ការគ្រប់គ្រងសំណល់រឹងនិងរាវ)។ល។ | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - រៀបចំការបណ្ដុះបណ្ដាលសម្រាប់ផ្នែកឯកជនអំពីតួនាទីនៃវិស័យទេសចរណ៍ដែលមានលក្ខណៈជាប្រព័ន្ធ តួនាទីរបស់ផ្នែកឯកជននៅក្នុងការអភិវឌ្ឍវិស័យអេកូទេសចរណ៍ ជំនាញអាជីវកម្ម ការស្វែងរកហិរញ្ញប្បទាន ការសិក្សាទីផ្សារ ការផ្គត់ផ្គង់ **"ផលិតផលខ្មែរបម្រើឱ្យភ្ញៀវទេសចរ"** និងការស្វែងយល់អំពីតម្រូវការភ្ញៀវទេសចរ។ល។ | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ជំរុញចលនាផ្សព្វផ្សាយការយល់ដឹងពីសក្ដានុពលធម្មជាតិ និងអេកូទេសចរណ៍ដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា ការរៀបចំជាចំរៀងទេសចរណ៍ និងស្ពតអប់រំ។ល។ | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- ក្រសួងព័ត៌មាន<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| | | | - រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - ត្រួតពិនិត្យនិងពង្រឹងសមត្ថភាពរបស់ស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាល ដែលជាគ្រូបង្គោលក្នុងការបណ្តុះបណ្តាលផ្នែកអេកូទេសចរណ៍ តាមរយៈការវាយតម្លៃសមត្ថភាពរបស់មន្ត្រីស្ថាប័ន ឬអង្គការក្រៅរដ្ឋាភិបាលទាំងនោះក្នុងការផ្តល់ការបណ្តុះបណ្តាល ការវាយតម្លៃអំពីកម្រិតតម្រូវការនៃការបណ្តុះបណ្តាល ការកសាងសមត្ថភាពបន្ថែមដល់អង្គការទាំងនោះនៅក្នុងករណីចាំបាច់ | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - បង្កើតកម្មវិធីអប់រំអេកូទេសចរណ៍ដែលមានលក្ខណៈទន់ភ្លន់ សម្រាប់ភ្ញៀវ**ទេសចរ**ឱ្យយល់ដឹងអំពីព័ត៌មានចាំបាច់មួយចំនួន ដូចជាប្រព័ន្ធអេកូឡូស៊ី ប្រវត្តិ និងវប្បធម៌របស់ប្រជាជនមូលដ្ឋាន តួនាទីរបស់ភ្ញៀវទេសចរក្នុងការចូលរួមដល់កិច្ចគាំពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិរបស់គោលដៅអេកូទេសចរណ៍ផ្សារភ្ជាប់នឹងមជ្ឈមណ្ឌលពត៌មានទេសចរណ៍ | ២០១៩-២០៣០ | - ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| | - រៀបចំកម្មវិធីអប់រំបណ្តុះបណ្តាលនិងផែនការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដល់**សហគមន៍** ប្រជាពលរដ្ឋមូលដ្ឋាន សិស្សានុសិស្ស(ចាប់ពីកម្រិតបឋមសិក្សា) ពីកិច្ចគាំពារបរិស្ថាននិងអភិរក្សធនធានធម្មជាតិ តាមរយៈការអភិវឌ្ឍអេកូទេសចរណ៍ | ២០១៩-២០៣០ | - ក្រុមការងារអន្តរក្រសួងគ្រប់គ្រងនិងអភិវឌ្ឍសហគមន៍ទេសចរណ៍និងអេកូទេសចរណ៍<br>- ក្រសួងទេសចរណ៍<br>- ក្រសួងបរិស្ថាន<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងស្ថាប័នពាក់ព័ន្ធ<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |